១.១-ដោយឈរលើមូលដ្ឋាននៃការគោរពគោលការណ៍ច្បាប់អន្តរជាតិ ក្នុងនោះគោលការណ៍ខ្សែព្រំដែនមិនកែប្រែដែលបន្សល់ទុកពីជំនាន់អាណានិគម ភាគីទាំងពីរឯកភាពចាត់ទុកខ្សែព្រំដែនដែលមាននៅពេលដែលប្រទេសទាំងពីរបានឯករាជ្យទុកជាមូលដ្ឋានសំខាន់ ដើម្បីកំណត់ព្រំដែនរដ្ឋរវាងប្រទេសទាំងពីរ។ ភាគីទាំងពីរឯកភាពអនុម័តយកគោលការណ៍ ដើម្បីដោះស្រាយបញ្ហាព្រំដែនរវាងប្រទេសទាំងពីរដូចខាងក្រោម៖

ក-ទទួលស្គាល់ខ្សែព្រំដែនរួម ដែលបន្សល់ទុកឲ្យដោយអាណានិគម តាមផែនទីខ្នាត ១/១០០ ០០០ និងផែនទីសមស្របផ្សេងៗទៀត ដែលធ្វើឡើងនៅចន្លោះឆ្នាំ១៩៣៣ ដល់ ឆ្នាំ១៩៥៣ ដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន

ខ-ទទួលស្គាល់គោលការណ៍ដែលទទួលស្គាល់ជាអន្តរជាតិក្នុងវិស័យកំណត់ព្រំដែន

គ-គិតគូរដល់ការកាន់កាប់ជាក់ស្តែងរបស់ប្រជាជនជាច្រើនជំនាន់មកហើយ

ឃ-ឈរលើស្មារតីសមភាព យុត្តិធម៌ សមធម៌ សម្រុះសម្រួល ការគោរពសិទ្ធិ និងផលប្រយោជន៍គ្នាទៅវិញទៅមក និងការឯកភាពលើទស្សនៈ។

១.២-ផ្អែកលើគោលការណ៍កំណត់ព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដូចបានលើកឡើងនៅក្នុងប្រការ ១ កថាខណ្ឌ ១.១ នៃសន្ធិសញ្ញានេះ និងផ្អែកលើកំណត់ហេតុនៃកិច្ចប្រជុំ កិច្ចព្រមព្រៀង និងកំណត់ហេតុបោះបង្គោលព្រំដែនរវាងប្រទេសទាំងពីរ កម្ពុជា-ឡាវ មានចំនួនឯកម្រិតនៃកិច្ចប្រជុំ ស្មើនឹងចំនួន ១៨៨ លើក ដែលក្នុងនោះ ភាគីទាំងពីរឯកភាពលើកយកកិច្ចព្រមព្រៀងចំនួន១ និងកំណត់ហេតុនៃកិច្ចប្រជុំចំនួន២០ សំខាន់ៗមកបញ្ចូលក្នុងសន្ធិសញ្ញានេះ រួមមាន៖(១)-កំណត់ហេតុស្តីពីកិច្ចប្រជុំលើកដំបូង រវាងគណៈកម្មការព្រំដែន កម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៥ នៅរដ្ឋធានីវៀងច័ន្ទ (២)-កំណត់ហេតុស្តីពីកិច្ចប្រជុំលើកទីពីរ រវាងគណៈកម្មការព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩៩៧ នៅរាជធានីភ្នំពេញ (៣)-កំណត់ហេតុកិច្ចប្រជុំលើកទី៣ រវាងគណៈកម្មការព្រំដែនកម្ពុជា-ឡាវ និង

ឡាវ-កម្ពុជា ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៨ នៅរដ្ឋធានីវៀងច័ន្ទ (៤)-កំណត់ហេតុកិច្ចប្រជុំលើកទី៤ រវាងគណៈកម្មការចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៩ នៅរាជធានីភ្នំពេញ (៥)-កំណត់ហេតុកិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មការចម្រុះព្រំដែន កម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០០ នៅរាជធានីភ្នំពេញ (៦)-កំណត់ហេតុកិច្ចប្រជុំលើកទី១ នៃអនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០០ នៅរាជធានីភ្នំពេញ (៧)-កំណត់ហេតុសម័យប្រជុំលើកទី២ របស់អនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០០ នៅទីក្រុងប៉ាក់សេ (៨)-បែបបទបច្ចេកទេសសម្រាប់ការចុះត្រួតពិនិត្យព្រំដែនរួម រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០០ នៅប៉ាក់សេ (៩)-កំណត់ហេតុស្តីពីការប្រជុំពិគ្រោះយោបល់រវាងក្រុមប្រតិបត្តិការកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ នៅរាជធានីភ្នំពេញ (១០)-កំណត់ហេតុកិច្ចប្រជុំលើកទី៣ នៃអនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០២ នៅទីក្រុងសៀមរាប (១១)-កំណត់ហេតុកិច្ចប្រជុំលើកទី៤ នៃអនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ នៅទីក្រុងប៉ាក់សេ (១២)-កំណត់ហេតុកិច្ចប្រជុំលើកទី៥ នៃគណៈកម្មការចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៣ នៅទីក្រុងហ្លួងប្រាបាង (១៣)-កំណត់ហេតុកិច្ចប្រជុំលើកទី៥ នៃអនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៣ នៅទីក្រុងហ្លួងប្រាបាង (១៤)-កំណត់ហេតុកិច្ចប្រជុំវិសាមញ្ញ នៃគណកម្មការចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៥ នៅរាជធានីភ្នំពេញ (១៥)-កំណត់ហេតុកិច្ចប្រជុំលើកទី៦ នៃអនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៥ នៅរាជធានីភ្នំពេញ (១៦)-កំណត់ហេតុកិច្ចប្រជុំរវាងប្រធានគណៈកម្មការបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៥ នៅទីក្រុងប៉ាក់សេ (១៧)-កំណត់ហេតុកិច្ចប្រជុំពិភាក្សារវាងក្រុមប្រតិបត្តិការចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៥ នៅខ្ទង-ចំប៉ាសាក់ (១៨)-កំណត់ហេតុកិច្ចប្រជុំវិសាមញ្ញនៃគណៈកម្មការចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី៧ ខែមករា ឆ្នាំ២០០៦ នៅរាជធានីភ្នំពេញ (១៩)-កំណត់ហេតុកិច្ចប្រជុំលើកទី៧ នៃអនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា ចុះថ្ងៃទី៧ ខែមករា ឆ្នាំ២០០៦ នៅរាជធានីភ្នំពេញ (២០)-កំណត់ហេតុកិច្ចប្រជុំរវាងឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៩ នៅខេត្តសៀមរាប និងកិច្ចព្រមព្រៀងចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ នៅរាជធានីភ្នំពេញ ដោយឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស រដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

បញ្ជីកំណត់ហេតុ និងកិច្ចព្រមព្រៀង ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ១ អមសន្ធិសញ្ញានេះ។

ផ្អែកលើឯកសារខាងលើ ភាគីទាំងពីរសម្រេចបានការត្រួតពិនិត្យខ្សែព្រំដែនរួម ប្រមាណជា ៨៦ភាគរយ(%) ស្មើនឹង ៤៦៥ គីឡូម៉ែត្រ នៃខ្សែព្រំដែនរួម។ ភាគីទាំងពីរឯកភាពគ្នាកំណត់ព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្នុងទិសដើរទូទៅនៃខ្សែព្រំដែនពីខាងលិចទៅខាងកើត ដោយចាប់ផ្ដើមចេញពីច្រកភ្នំព្រះចំបុក នៅចំណុចប្រសព្វនៃព្រំដែនទាំងបីប្រទេស រវាងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងព្រះរាជាណាចក្រថៃឡង់ដ៍ និងបញ្ចប់ទៅវិញនៅទិសខាងកើត នៅចំណុចប្រសព្វនៃព្រំដែនបីប្រទេស រវាងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដោយបានបោះបង្គោលព្រំដែនរួចរាល់នៅលើដីជាក់ស្ដែងបានចំនួន ១២១ បង្គោល ដូចមាននិយាមការង់វែងចេញពីផែនទីអ៊ុយតេអ៊ឹម (UTM) ខ្នាត ១/៥០ ០០០ ដែលត្រូវបានគណនាឯកតាជាម៉ែត្រ ដូចខាងក្រោម ៖

បង្គោលលេខ 024 ជាបង្គោលភ្លោះ ស្ថិតនៅត្រើយសងខាងទន្លេមេគង្គ។ បង្គោល C-024 ស្ថិតនៅត្រើយខាងស្ដាំទន្លេមេគង្គ ភូមិកំពង់សង្កែ ក្នុងទឹកដីកម្ពុជា ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º05'34.674" រយៈទទឹងខាងជើង 105º 44'43.010" រយៈបណ្ដោយខាងកើត មានចម្ងាយ 132 ម៉ែត្រ ពីខ្សែព្រំដែន ។ បង្គោល L-024 ស្ថិតនៅត្រើយខាងឆ្វេង ទន្លេមេគង្គ ភូមិកោះស្នោ ក្នុងទឹកដីឡាវ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º05'42.117" រយៈទទឹងខាងជើង 105º44'46.637" រយៈបណ្ដោយខាងកើត មានចម្ងាយ 121 ម៉ែត្រ ពីខ្សែព្រំដែន ។ ពីបង្គោលលេខ 024 ខ្សែព្រំដែនដើរតាមពាក់កណ្ដាលទន្លេមេគង្គ ចន្លោះដើមភូមិកំពុងសង្កែ និងកោះស្នោ ទៅទិសរួមខាងកើត (បូព៌ា) ដល់ទីតាំងបង្គោលភ្លោះលេខ 025 ស្ថិតនៅត្រើយសងខាងទន្លេមេគង្គ ។ បង្គោល C-025 ស្ថិតនៅត្រើយខាងស្ដាំទន្លេមេគង្គ ភូមិកំពង់ស្រឡៅ ក្នុងទឹកដីកម្ពុជា ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º04'55.920" រយៈទទឹងខាងជើង 105º47'12.059" រយៈបណ្ដោយខាងកើត មានចម្ងាយ 138 ម៉ែត្រ ពីខ្សែព្រំដែន ។ បង្គោល L-025 ស្ថិតនៅត្រើយខាងឆ្វេងទន្លេមេគង្គ ភូមិកន្ទុយកោះស្នោ ក្នុងទឹកដីឡាវត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º05'02.906" រយៈទទឹងខាងជើង 105º47'16.085" រយៈបណ្ដោយខាងកើត មានចម្ងាយ 108 ម៉ែត្រ ពីខ្សែព្រំដែន ។ ពីបង្គោលលេខ 025 ខ្សែព្រំដែនដើរតាមពាក់កណ្ដាលទន្លេមេគង្គ ចន្លោះភូមិកំពង់ស្រឡៅ និងកោះស្នោ ទៅទិសខាងកើត រួចប្តូរទៅទិសខាងត្បូង(ទក្សិណ) ដល់ទីតាំងបង្គោលភ្លោះលេខ 026 ស្ថិតនៅត្រើយសងខាងទន្លេមេគង្គ ។ បង្គោល C-026 ស្ថិតនៅត្រើយខាងស្ដាំទន្លេមេគង្គ ចន្លោះភូមិកំពង់ពោធិ និងកំពង់ក្រសាំង ក្នុងទឹកដីកម្ពុជាត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º02'59.658" រយៈទទឹងខាងជើង 105º47'09.094" រយៈបណ្ដោយខាងកើត មានចម្ងាយ

349 ម៉ែត្រ ពីខ្សែព្រំដែន ។ បង្គោល L-026 ស្ថិតនៅត្រើយខាងឆ្វេងទន្លេមេគង្គ កោះកានហ៊ុង ក្នុងទឹកដីឡាវត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º03'04.336" រយៈទទឹងខាងជើង 105º47'31.918" រយៈបណ្តោយខាងកើត មានចម្ងាយ 350 ម៉ែត្រ ពីខ្សែព្រំដែន ។ ពីបង្គោលលេខ 026 ខ្សែព្រំដែនដើរតាមទន្លេមេគង្គ ចន្លោះភូមិកំពង់ពោធិ៍ និងកំពង់ក្រសាំង(កម្ពុជា) កោះកានហ៊ុង ភូមិកាឌិន(ឡាវ) ទៅទិសខាងត្បូង(ទក្សិណ) ដល់ទីតាំងបង្គោលភ្លោះលេខ 026/1 ស្ថិតនៅត្រើយសងខាងនៃទន្លេមេគង្គ នៅភូមិកំពង់ក្រសាំង(កម្ពុជា) កោះកានហ៊ុង ភូមិកាឌិន(ឡាវ) ។ បង្គោល C-026/1 ស្ថិតនៅត្រើយខាងស្តាំទន្លេមេគង្គ នៅភូមិកំពង់ក្រសាំង ក្នុងទឹកដីកម្ពុជាត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º02'23.997" រយៈទទឹងខាងជើង 105º47'14.374" រយៈបណ្តោយខាងកើត មានចម្ងាយ 336 ម៉ែត្រ ពីខ្សែព្រំដែន ។ បង្គោល L-026/1 ស្ថិតនៅត្រើយខាងឆ្វេងទន្លេមេគង្គ លើកោះកាឌិន ក្នុងទឹកដីឡាវត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º 02'24.114" រយៈទទឹងខាងជើង 105º47'38.515" រយៈបណ្តោយខាងកើត មានចម្ងាយ 389 ម៉ែត្រ ពីខ្សែព្រំដែន។ ពីបង្គោលលេខ 026/1 ខ្សែព្រំដែនដើរតាមទន្លេមេគង្គ ចន្លោះភូមិកំពង់ពោធិ៍ និងកំពង់ក្រសាំង(កម្ពុជា) កោះកានហ៊ុង ភូមិកាឌិន(ឡាវ) ទៅទិសឦសានអាគ្នេយ៍ ដល់ទីតាំងបង្គោលភ្លោះលេខ 027 ស្ថិតនៅត្រើយសងខាងទន្លេមេគង្គ។ បង្គោល C-027 ស្ថិតនៅត្រើយខាងស្តាំទន្លេមេគង្គ លើកោះសន ភូមិកំពង់អំពិល ក្នុងទឹកដីកម្ពុជា ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º00'41.123" រយៈទទឹងខាងជើង 105º48'24.703" រយៈបណ្តោយខាងកើត មានចម្ងាយ 405 ម៉ែត្រ ពីខ្សែព្រំដែន ។ បង្គោល L-027 ស្ថិតនៅត្រើយខាងឆ្វេង ទន្លេមេគង្គ កន្ទុយកោះលោង ក្នុងទឹកដីឡាវ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º00'59.176" រយៈទទឹងខាងជើង 105º48'40.969" រយៈបណ្តោយខាងកើត មានចម្ងាយ 334.6 ម៉ែត្រ ពីខ្សែព្រំដែន ។ ពីបង្គោលលេខ 027 ខ្សែព្រំដែនដើរតាមទន្លេមេគង្គ ចន្លោះកោះសន(កម្ពុជា) កន្ទុយកោះលោង(ឡាវ) ទៅទិសឦសានអាគ្នេយ៍ ដល់ទីតាំងបង្គោលភ្លោះលេខ 028 ស្ថិតនៅត្រើយសងខាងទន្លេមេគង្គ។ បង្គោល C-028 ស្ថិតនៅត្រើយខាងស្តាំទន្លេមេគង្គ ភូមិកំពង់ព្រះឥន្ទ ក្នុងទឹកដីកម្ពុជា ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 13º58'23.775" រយៈទទឹងខាងជើង 105º51'23.16" រយៈបណ្តោយខាងកើត មានចម្ងាយ 125 ម៉ែត្រពីខ្សែព្រំដែន ។ បង្គោល L-028 ស្ថិតនៅត្រើយខាងឆ្វេងទន្លេមេគង្គ កន្ទុយកោះញ៉ាវ ក្នុងទឹកដីឡាវ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 13º58'33.102" រយៈទទឹងខាងជើង 105º51'27.294" រយៈបណ្តោយខាងកើត មានចម្ងាយ 187 ម៉ែត្រពីខ្សែព្រំដែន ។ ពីបង្គោលលេខ 028 ខ្សែព្រំដែនដើរតាមទន្លេមេគង្គ ចន្លោះភូមិកំពង់ព្រះឥន្ទ(កម្ពុជា) និងកោះញ៉ាវ គមកោះសូម(ឡាវ) ទៅទិសឦសានអាគ្នេយ៍ ដល់ទីតាំងបង្គោលភ្លោះលេខ 029 ។

បង្គោលលេខ 031/1 មានទីតាំងស្ថិតនៅលើខ្សែបែងចែកទឹក ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 105°59'43.492" រយៈបណ្តោយខាងកើត 13°55'25.937" រយៈទទឹងខាងជើង។ ពីបង្គោលលេខ 031/1 ខ្សែព្រំដែនដើរទៅទិសខាងជើង(ឧត្តរ) តាមខ្សែបែងចែកទឹក ដល់បង្គោលលេខ 031/2 មានទីតាំងស្ថិតនៅលើខ្សែបែងចែកទឹក ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 13°55'30.723" រយៈទទឹងខាងជើង 105°59'43.146" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 031/2 ខ្សែព្រំដែនបន្តដើរទៅទិសខាងជើងតាមខ្សែបែងចែកទឹក ដល់បង្គោលលេខ 031/3 មានទីតាំងស្ថិតនៅលើខ្សែបែងចែកទឹក ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 13°55'33.252" រយៈទទឹងខាងជើង 105°59'45.523" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 031/3 ខ្សែព្រំដែនបន្តដើរទៅទិសឦសាន តាមខ្សែបែងចែកទឹក ដល់បង្គោលលេខ 031/4 មានទីតាំងស្ថិតនៅលើខ្សែបែងចែកទឹក ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 13°55'36.761" រយៈទទឹងខាងជើង 105°59'47.104" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 031/4 ខ្សែព្រំដែនបន្តដើរទៅទិសឦសាន តាមខ្សែបែងចែកទឹក ដល់បង្គោលលេខ 031/5 មានទីតាំងស្ថិតនៅលើខ្សែបែងចែកទឹក ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 105°59'48.775" រយៈបណ្តោយខាងកើត 13°55'37.764" រយៈទទឹងខាងជើង។ ពីបង្គោលលេខ 031/5 ខ្សែព្រំដែនបន្តដើរទៅទិសឦសាន តាមខ្សែបែងចែកទឹក ដល់បង្គោលលេខ 031/6 មានទីតាំងស្ថិតនៅលើខ្សែបែងចែកទឹក ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 13°55'39.737" រយៈទទឹងខាងជើង 105°59'51.849" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 031/6 ខ្សែព្រំដែនបន្តដើរទៅទិសពាយ័ព្យ តាមខ្សែបែងចែកទឹក ដល់បង្គោលលេខ 032 មានទីតាំងស្ថិតនៅលើខ្នងភ្នំខ្លាឃ្មុំ(ឌុងមី) ក្បែរផ្លូវឆ្ពោះទៅវ៉ឺនខាំ ដែលជាផ្លូវបែកចេញពីផ្លូវជាតិលេខ13(ភាគខាងត្បូងឡាវ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 13°55'43.584" រយៈទទឹងខាងជើង 105°59'50.133" រយៈបណ្តោយខាងកើត រួចបន្តដើរទៅទិសរួមខាងកើត (បូព៌ា)។

បង្គោលលេខ 032/6 មានទីតាំងស្ថិតនៅខាងកើតផ្លូវ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 13°55'41.682" រយៈទទឹងខាងជើង 106°00'33.082" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 032/6 ខ្សែព្រំដែនដើរទៅទិសខាងកើត(បូព៌ា) ឆ្ពោះទៅកំពូលភ្នំគ្មានឈ្មោះ រហូតដល់បង្គោលលេខ 032/7 មានទីតាំងស្ថិតនៅលើកំពូលភ្នំគ្មានឈ្មោះ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 13°55'40.966" រយៈទទឹងខាងជើង 106°00'40.910" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 032/7 ខ្សែព្រំដែនប្តូរទិសទៅទិសអាគ្នេយ៍ តាមខ្នងទួលរហូតដល់បង្គោលលេខ 032/8 មានទីតាំងស្ថិតនៅលើខ្នងទួល ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 13°55'36.634" រយៈទទឹងខាងជើង 106°00'49.556" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 032/8 ខ្សែព្រំដែនបន្តដើរទៅទិសខាងកើត(បូព៌ា) តាមខ្នងទួលរហូតដល់បង្គោលលេខ 032/9 មានទីតាំងស្ថិតនៅលើខ្នងទួល ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 106°00'57.354" រយៈបណ្តោយខាង

ឧបសម្ព័ន្ធ ៤

**បញ្ជីកំណាត់ព្រំដែន**
**ដែលបានចុះត្រួតពិនិត្យ និងមិនទាន់បានចុះត្រួតពិនិត្យ**
**ទុកបន្តការពិភាក្សា និងដោះស្រាយក្រោយចុះសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ**
**រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ**

* * * * * *

I-កំណាត់ព្រំដែនដែលបានចុះត្រួតពិនិត្យរួច៖

១- កំណាត់ខ្សែព្រំដែន ចាប់ពីច្រកព្រះចំបុក(មុំបី) ដល់បង្គោលព្រំដែនលេខ ០២៤ នៅខេត្តព្រះវិហារ (កម្ពុជា) និងខេត្តចំប៉ាសាក់ (ឡាវ)

២- កំណាត់ខ្សែព្រំដែននៅចន្លោះបង្គោលលេខ ០២៩-០៣១/១ នៅខេត្តស្ទឹងត្រែង (កម្ពុជា) និងខេត្តចំប៉ាសាក់ (ឡាវ)

៣- កំណាត់ខ្សែព្រំដែននៅចន្លោះបង្គោលលេខ ០៣២-០៣២/៦ នៅខេត្តស្ទឹងត្រែង (កម្ពុជា) និងខេត្តចំប៉ាសាក់ (ឡាវ)

៤- កំណាត់ខ្សែព្រំដែននៅចន្លោះបង្គោលលេខ ០៣៣-០៣៤ នៅខេត្តស្ទឹងត្រែង (កម្ពុជា) និងខេត្តចំប៉ាសាក់ (ឡាវ)

៥- កំណាត់ខ្សែព្រំដែននៅចន្លោះបង្គោលលេខ ០៣៧-០៤០ នៅខេត្តស្ទឹងត្រែង (កម្ពុជា) និងខេត្តចំប៉ាសាក់ (ឡាវ)

II-កំណាត់ព្រំដែនដែលមិនទាន់បានចុះត្រួតពិនិត្យ៖

១- កំណាត់ខ្សែព្រំដែននៅចន្លោះបង្គោលលេខ ០៧៨-០៩៩ រវាងខេត្តស្ទឹងត្រែង/រតនគិរី (កម្ពុជា) និងខេត្តចំប៉ាសាក់/អាត់តាពើ (ឡាវ)

ឧបសម្ព័ន្ធ ៣

## បញ្ជីកំណាត់ព្រំដែន និងទីតាំងបង្គោលព្រំដែនមិនទាន់ឯកភាព ទុកបន្តការពិភាក្សា និងដោះស្រាយក្រោយចុះសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

* * * * * * *

១-តំបន់ប្រភពទន្លេពៅ/Selam Pao (ពីបង្គោលព្រំដែនលេខ ០០២ ដល់លេខ ០០៣)

២-តំបន់អូរស្វាយ/Veun Kham (ចំណុចខ្សែព្រំដែនឡើងគោក និងពីបង្គោលព្រំដែនលេខ ០៣១ ដល់លេខ ០៣១/១)

៣-កំណាត់បង្គោលព្រំដែនលេខ ០៣២ ដល់លេខ ០៣២/៦

៤-កំណាត់ខ្សែព្រំដែនតំបន់ដុងក្រឡតាមបណ្តោយផ្លូវជាតិលេខ៧ (កម្ពុជា) និងលេខ១៣ (ឡាវ) (ពីបង្គោលព្រំដែនលេខ ០៣៣ ដល់លេខ ០៣៤)

| | | | | | |
|---|---|---|---|---|---|
| 114 | 138 | 765752 | 1616575 | 107° 28' 01.916" | 14° 36' 38.247" |
| 115 | 139 | 768069 | 1617994 | 107° 29' 19.822" | 14° 37' 23.572" |
| 116 | 140 | 769362 | 1618929 | 107° 30' 03.354" | 14° 37' 53.517" |
| 117 | 141 | 770483 | 1619760 | 107° 30' 41.105" | 14° 38' 20.138" |
| 118 | 142 | 771488 | 1620649 | 107° 31' 15.005" | 14° 38' 48.686" |
| 119 | 143 | 772276 | 1622311 | 107° 31' 41.947" | 14° 39' 42.449" |
| 120 | 144 | 772372 | 1624407 | 107° 31' 45.938" | 14° 40' 50.576 |
| 121 | 145 | 773937 | 1624977 | 107° 32' 38.437" | 14° 41' 08.541" |

| | | | | | |
|---|---|---|---|---|---|
| 71 | 75 | 640343 | 1597727 | 106° 18' 08.043" | 14° 26' 58.746" |
| 72 | 76 | 641726 | 1597511 | 106° 18' 54.191" | 14° 26' 51.460" |
| 73 | 77 | 642163 | 1596581 | 106° 19' 08.607" | 14° 26' 21.112" |
| | 77 | 642187 | 1596616 | 106° 19' 09.415" | 14° 26' 22.247" |
| 74 | 78 | 643752 | 1596263 | 106° 20' 01.612" | 14° 26' 10.465" |
| | 78 | 643790 | 1596311 | 106° 20' 02.890" | 14° 26' 12.020" |
| 75 | 99 | 694943 | 1583687 | 106° 48' 27.679" | 14° 19' 09.895" |
| 76 | 100 | 698494 | 1582140 | 106° 50' 25.767" | 14° 18' 18.651" |
| 77 | 101 | 700118 | 1580840 | 106° 51' 19.610" | 14° 17' 35.933" |
| 78 | 102 | 702267 | 1583459 | 106° 52' 32.020" | 14° 19' 00.582" |
| 79 | 103 | 704305 | 1582985 | 106° 53' 39.896" | 14° 18' 44.620" |
| 80 | 104 | 704018 | 1585202 | 106° 53' 30.924" | 14° 19' 56.827" |
| 81 | 105 | 706365 | 1585003 | 106° 54' 49.190" | 14° 19' 49.725" |
| 82 | 106 | 710316 | 1583055 | 106° 57' 00.487" | 14° 18' 45.275" |
| 83 | 107 | 712642 | 1583053 | 106° 58' 18.097" | 14° 18' 44.570" |
| 84 | 108 | 712915 | 1586025 | 106° 58' 28.052" | 14° 20' 21.184" |
| 85 | 109 | 713538 | 1588024 | 106° 58' 49.413" | 14° 21' 26.045" |
| 86 | 110 | 716475 | 1589841 | 107° 00' 27.956" | 14° 22' 24.332" |
| 87 | 111 | 718437 | 1592958 | 107° 01' 34.352" | 14° 24' 05.177" |
| 88 | 112 | 721022 | 1594368 | 107° 03' 01.054" | 14° 24' 50.303" |
| 89 | 113 | 720580 | 1598096 | 107° 02' 47.408" | 14° 26' 51.710" |
| 90 | 114 | 724448 | 1595630 | 107° 04' 55.793" | 14° 25' 30.356" |
| 91 | 115 | 725015 | 1592233 | 107° 05' 13.692" | 14° 23' 39.681" |
| 92 | 116 | 729117 | 1592400 | 107° 07' 30.650" | 14° 23' 43.894" |
| 93 | 117 | 730596 | 1594445 | 107° 08' 20.647" | 14° 24' 49.972" |
| 94 | 118 | 734728 | 1595328 | 107° 10' 38.842" | 14° 25' 17.435" |
| 95 | 119 | 736922 | 1597717 | 107° 11' 52.836" | 14° 26' 34.466" |
| 96 | 120 | 737628 | 1601311 | 107° 12' 17.556" | 14° 28' 31.153" |
| 97 | 121 | 739189 | 1602635 | 107° 13' 10.099" | 14° 29' 13.730" |
| 98 | 122 | 741857 | 1601708 | 107° 14' 38.872" | 14° 28' 42.731" |
| 99 | 123 | 743238 | 1605055 | 107° 15' 26.079" | 14° 30' 31.158" |
| 100 | 124 | 744035 | 1608662 | 107° 15' 53.885" | 14° 32' 28.226" |
| 101 | 125 | 746660 | 1610445 | 107° 17' 22.142" | 14° 33' 25.368" |
| 102 | 126 | 746813 | 1612943 | 107° 17' 28.091" | 14° 34' 46.569" |
| 103 | 127 | 749964 | 1613616 | 107° 19' 13.561" | 14° 35' 07.419" |
| 104 | 128 | 752864 | 1612783 | 107° 20' 50.131" | 14° 34' 39.358" |
| 105 | 129 | 754966 | 1610198 | 107° 21' 59.435" | 14° 33' 14.574" |
| 106 | 130 | 756274 | 1608599 | 107° 22' 42.557" | 14° 32' 22.125" |
| 107 | 131 | 758705 | 1608790 | 107° 24' 03.797" | 14° 32' 27.509" |
| 108 | 132 | 761226 | 1607307 | 107° 25' 27.449" | 14° 31' 38.410" |
| 109 | 133 | 764240 | 1607208 | 107° 27' 08.045" | 14° 31' 34.143" |
| 110 | 134 | 764716 | 1608125 | 107° 27' 24.267" | 14° 32' 03.799" |
| 111 | 135 | 764858 | 1610273 | 107° 27' 29.781" | 14° 33' 13.607" |
| 112 | 136 | 764562 | 1613495 | 107° 27' 21.058" | 14° 34' 58.498" |
| 113 | 137 | 766140 | 1614204 | 107° 28' 14.013" | 14° 35' 21.000" |

| | | | | | |
|---|---|---|---|---|---|
| 29 | 35 | 619479 | 1543727 | 106° 06' 22.651" | 13° 57' 44.761" |
| 30 | 36 | 619582 | 1547001 | 106° 06' 26.594" | 13° 59' 31.307" |
| 31 | 37 | 623440 | 1549615 | 106° 08' 35.613" | 14° 00' 55.790" |
| 32 | 38 | 626734 | 1550212 | 106° 10' 25.521" | 14° 01' 14.695" |
| | 38 | 626724 | 1550272 | 106° 10' 25.198" | 14° 01' 16.650" |
| 33 | 39 | 628640 | 1554496 | 106° 11' 29.782" | 14° 03' 33.815" |
| | 39 | 628583 | 1554530 | 106° 11' 27.887" | 14° 03' 34.931" |
| 34 | 40 | 623901 | 1557665 | 106° 08' 52.287" | 14° 05' 17.722" |
| | 40 | 623829 | 1557661 | 106° 08' 49.885" | 14° 05' 17.603" |
| 35 | 41 | 623032 | 1558776 | 106° 08' 23.488" | 14° 05' 54.019" |
| 36 | 42 | 620644 | 1562493 | 106° 07' 04.442" | 14° 07' 55.371" |
| 37 | 43 | 620380 | 1564729 | 106° 06' 55.991" | 14° 09' 08.188" |
| 38 | 44 | 620006 | 1568357 | 106° 06' 44.091" | 14° 11' 06.327" |
| 39 | 45 | 616689 | 1568904 | 106° 04' 53.516" | 14° 11' 24.637" |
| 40 | 46 | 613881 | 1570819 | 106° 03' 20.122" | 14° 12' 27.384" |
| 41 | 47 | 612128 | 1572812 | 106° 02' 21.929" | 14° 13' 32.508" |
| 42 | 48 | 611237 | 1574891 | 106° 01' 52.505" | 14° 14' 40.304" |
| 43 | 49 | 611100 | 1576524 | 106° 01' 48.175" | 14° 15' 33.474" |
| 44 | 50 | 611787 | 1578352 | 106° 02' 11.374" | 14° 16' 32.872" |
| 45 | 51 | 610232 | 1582429 | 106° 01' 20.075" | 14° 18' 45.794" |
| 46 | 52 | 608546 | 1582840 | 106° 00' 23.854" | 14° 18' 59.412" |
| 47 | 53 | 608397 | 1585506 | 106° 00' 19.266" | 14° 20' 26.206" |
| 48 | 54 | 607765 | 1586314 | 105° 59' 58.283" | 14° 20' 52.594" |
| 49 | 55 | 608423 | 1588751 | 106° 00' 20.606" | 14° 22' 11.820" |
| 50 | 56 | 611987 | 1585697 | 106° 02' 19.148" | 14° 20' 31.906" |
| 51 | 57 | 614609 | 1585576 | 106° 03' 46.665" | 14° 20' 27.580" |
| 52 | 58 | 616856 | 1584891 | 106° 05' 01.573" | 14° 20' 04.946" |
| 53 | 59/1 | 617682 | 1587049 | 106° 05' 29.488" | 14° 21' 15.056" |
| 54 | 59/2 | 617697 | 1587109 | 106° 05' 29.998" | 14° 21' 17.007" |
| 55 | 60 | 617749 | 1588146 | 106° 05' 31.898" | 14° 21' 50.750" |
| 56 | 61 | 619397 | 1589198 | 106° 06' 27.089" | 14° 22' 24.734" |
| 57 | 62 | 621374 | 1587203 | 106° 07' 32.775" | 14° 21' 19.492" |
| 58 | 63 | 622259 | 1587838 | 106° 08' 02.426" | 14° 21' 40.018" |
| 59 | 64 | 623802 | 1588827 | 106° 08' 54.106" | 14° 22' 11.958" |
| 60 | 65 | 625877 | 1586738 | 106° 10' 03.033" | 14° 21' 03.631" |
| 61 | 66/1 | 628462 | 1586456 | 106° 11' 29.285" | 14° 20' 54.023" |
| 62 | 66/2 | 628498 | 1586454 | 106° 11' 30.486" | 14° 20' 53.952" |
| 63 | 67 | 630274 | 1588918 | 106° 12' 30.207" | 14° 22' 13.845" |
| 64 | 68 | 632558 | 1590076 | 106° 13' 46.670" | 14° 22' 51.139" |
| 65 | 69 | 633938 | 1593472 | 106° 14' 33.358" | 14° 24' 41.422" |
| 66 | 70 | 635244 | 1597158 | 106° 15' 17.641" | 14° 26' 41.152" |
| 67 | 71 | 634200 | 1598875 | 106° 14' 43.084" | 14° 27' 37.217" |
| 68 | 72 | 636068 | 1601479 | 106° 15' 45.955" | 14° 29' 01.631" |
| 69 | 73 | 636999 | 1600028 | 106° 16' 16.785" | 14° 28' 14.241" |
| 70 | 74 | 639895 | 1599518 | 106° 17' 53.419" | 14° 27' 57.115" |

ឧបសម្ព័ន្ធ ២

## តារាងនិយាមការបង្គោលព្រំដែនចំនួន ១២១ បង្គោល ដែលភាគីទាំងពីរបានឯកភាពគ្នា

* * * * * *

| No | BP | E | N | Longitude | Latitude |
|---|---|---|---|---|---|
| 1 | 24 | 580442 | 1558011 | 105° 44' 43.010" | 14° 05' 34.674" |
| | 24 | 580550 | 1558240 | 105° 44' 46.637" | 14° 05' 42.117" |
| 2 | 25 | 584915 | 1556835 | 105° 47' 12.059" | 14° 04' 55.920" |
| | 25 | 585035 | 1557050 | 105° 47' 16.085" | 14° 05' 02.906" |
| 3 | 26 | 584838 | 1553263 | 105° 47' 09.094" | 14° 02' 59.658" |
| | 26 | 585522 | 1553409 | 105° 47' 31.918" | 14° 03' 04.336" |
| 4 | 26/1 | 585000 | 1552168 | 105° 47' 14.374" | 14° 02' 23.997" |
| | 26/1 | 585724 | 1552174 | 105° 47' 38.515" | 14° 02' 24.114" |
| 5 | 27 | 587120 | 1549018 | 105° 48' 24.703" | 14° 00' 41.230" |
| | 27 | 587606 | 1549571 | 105° 48' 40.969" | 14° 00' 59.176" |
| 6 | 28 | 592488 | 1544814 | 105° 51' 23.160" | 13° 58' 23.775" |
| | 28 | 592611 | 1545101 | 105° 51' 27.294" | 13° 58' 33.102" |
| 7 | 29 | 597485 | 1540568 | 105° 54' 09.187" | 13° 56' 04.965" |
| | 29 | 597686 | 1540830 | 105° 54' 15.919" | 13° 56' 13.468" |
| 8 | 30 | 602652 | 1540047 | 105° 57' 01.318" | 13° 55' 47.351" |
| | 30 | 602644 | 1540162 | 105° 57' 01.066" | 13° 55' 51.096" |
| 9 | 31/1 | 607521 | 1539409 | 105° 59' 43.492" | 13° 55' 25.937" |
| 10 | 31/2 | 607510 | 1539556 | 105° 59' 43.146" | 13° 55' 30.723" |
| 11 | 31/3 | 607581 | 1539634 | 105° 59' 45.523" | 13° 55' 33.252" |
| 12 | 31/4 | 607628 | 1539742 | 105° 59' 47.104" | 13° 55' 36.761" |
| 13 | 31/5 | 607678 | 1539773 | 105° 59' 48.775" | 13° 55' 37.764" |
| 14 | 31/6 | 607770 | 1539834 | 105° 59' 51.849" | 13° 55' 39.737" |
| 15 | 32 | 607718 | 1539952 | 105° 59' 50.133" | 13° 55' 43.584" |
| 16 | 32/6 | 609007 | 1539899 | 106° 00' 33.082" | 13° 55' 41.682" |
| 17 | 32/7 | 609242 | 1539878 | 106° 00' 40.910" | 13° 55' 40.966" |
| 18 | 32/8 | 609502 | 1539746 | 106° 00' 49.556" | 13° 55' 36.634" |
| 19 | 32/9 | 609736 | 1539744 | 106° 00' 57.354" | 13° 55' 36.536" |
| 20 | 32/10 | 609997 | 1539616 | 106° 01' 06.033" | 13° 55' 32.334" |
| 21 | 32/11 | 610091 | 1539564 | 106° 01' 09.158" | 13° 55' 30.628" |
| 22 | 32/12 | 610330 | 1539596 | 106° 01' 17.127" | 13° 55' 31.636" |
| 23 | 32/13 | 610626 | 1539393 | 106° 01' 26.962" | 13° 55' 24.988" |
| 24 | 32/14 | 610901 | 1539303 | 106° 01' 36.114" | 13° 55' 22.020" |
| 25 | 32/15 | 611139 | 1539314 | 106° 01' 44.046" | 13° 55' 22.344" |
| 26 | 32/16 | 611264 | 1539300 | 106° 01' 48.210" | 13° 55' 21.871" |
| 27 | 32/17 | 611460 | 1539250 | 106° 01' 54.734" | 13° 55' 20.216" |
| 28 | 34 | 619984 | 1538713 | 106° 06' 38.702" | 13° 55' 01.489" |

| | | |
|---|---|---|
| ១១ | កំណត់ហេតុនៃកិច្ចប្រជុំលើកទី ៤ នៃអនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា | ទីក្រុងប៉ាក់សេ, ថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ |
| ១២ | កំណត់ហេតុកិច្ចប្រជុំលើកទី៥ នៃគណៈកម្មការចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា | ទីក្រុងហ្លួងប្រាបាង, ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៣ |
| ១៣ | កំណត់ហេតុកិច្ចប្រជុំលើកទី៥ នៃអនុគណៈកម្មការបច្ចេកទេស ចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា | ទីក្រុងហ្លួងប្រាបាង, ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៣ |
| ១៤ | កំណត់ហេតុកិច្ចប្រជុំវិសាមញ្ញ នៃគណកម្មការចម្រុះព្រំដែន កម្ពុជា-ឡាវ និងឡាវ-កម្ពុជា | រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៥ |
| ១៥ | កំណត់ហេតុកិច្ចប្រជុំលើកទី៦ នៃអនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែន កម្ពុជា-ឡាវ និងឡាវ-កម្ពុជា | រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៥ |
| ១៦ | កំណត់ហេតុកិច្ចប្រជុំរវាងប្រធានគណៈម្មការបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា | ទីក្រុងប៉ាក់សេ, ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៥ |
| ១៧ | កំណត់ហេតុកិច្ចប្រជុំពិភាក្សា រវាងក្រុមប្រតិបត្តិការចម្រុះព្រំដែន កម្ពុជា-ឡាវ និងឡាវ-កម្ពុជា | ចំប៉ាសាក់, ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៥ |
| ១៨ | កំណត់ហេតុកិច្ចប្រជុំវិសាមញ្ញនៃគណៈកម្មការចម្រុះព្រំដែន កម្ពុជា-ឡាវ និងឡាវ-កម្ពុជា | រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែមករា ឆ្នាំ២០០៦ |
| ១៩ | កំណត់ហេតុកិច្ចប្រជុំលើកទី៧ នៃអនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែន កម្ពុជា-ឡាវ និងឡាវ-កម្ពុជា | រាជធានីភ្នំពេញ, ថ្ងៃទី៧ ខែមករា ឆ្នាំ២០០៦ |
| ២០ | កំណត់ហេតុកិច្ចប្រជុំរវាងឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និងឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេស នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ | សៀមរាប, ថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៩ |
| ២១ | កិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្ដីពី ការកំណត់ព្រំដែននៃប្រទេសទាំងពីរ | រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ |

ឧបសម្ព័ន្ធ ១

**បញ្ជីកំណត់ហេតុ និងកិច្ចព្រមព្រៀង ចំនួន២១ ភ្ជាប់ជាឧបសម្ព័ន្ធនៃ**
**សន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ**

*****

| ល.រ | ឈ្មោះឯកសារ | ទីកន្លែង និងកាលបរិច្ឆេទ ចុះហត្ថលេខា |
|---|---|---|
| ១ | កំណត់ហេតុស្ដីពីកិច្ចប្រជុំលើកដំបូង រវាងគណៈកម្មការព្រំដែន កម្ពុជា-ឡាវ និងឡាវ-កម្ពុជា | រដ្ឋធានីវៀងច័ន្ទ, ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៥ |
| ២ | កំណត់ហេតុស្ដីពីកិច្ចប្រជុំលើកទីពីរ រវាងគណៈកម្មការព្រំដែន កម្ពុជា-ឡាវ និងឡាវ-កម្ពុជា | រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ១៩៩៧ |
| ៣ | កំណត់ហេតុនៃកិច្ចប្រជុំលើកទី៣ រវាងគណៈកម្មការព្រំដែន កម្ពុជា-ឡាវ និងឡាវ-កម្ពុជា | រដ្ឋធានីវៀងច័ន្ទ, ថ្ងៃទី ១៥ ខែមករា ឆ្នាំ១៩៩៨ |
| ៤ | កំណត់ហេតុនៃកិច្ចប្រជុំលើកទី៤ រវាងគណៈកម្មការចម្រុះព្រំដែន កម្ពុជា-ឡាវ និងឡាវ-កម្ពុជា | រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៩ |
| ៥ | កំណត់ហេតុនៃកិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មការចម្រុះព្រំដែន កម្ពុជា-ឡាវ និងឡាវ-កម្ពុជា | រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០០ |
| ៦ | កំណត់ហេតុសម័យប្រជុំលើកទី១ នៃអនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែន កម្ពុជា-ឡាវ និងឡាវ-កម្ពុជា | រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០០ |
| ៧ | កំណត់ហេតុនៃសម័យប្រជុំលើកទី២ របស់អនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែន កម្ពុជា-ឡាវ និងឡាវ-កម្ពុជា | ទីក្រុងប៉ាក់សេ, ថ្ងៃទី១០ ខែមេសា ឆ្នាំ២០០០ |
| ៨ | បែបបទបច្ចេកទេសសម្រាប់ការចុះត្រួតពិនិត្យព្រំដែនរួម រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ | ប៉ាក់សេ, ថ្ងៃទី១០ ខែមេសា ឆ្នាំ២០០០ |
| ៩ | កំណត់ហេតុស្ដីពីការប្រជុំពិគ្រោះយោបល់រវាងក្រុមប្រត្តិបត្តិការ កម្ពុជា-ឡាវ និងឡាវ-កម្ពុជា | រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ |
| ១០ | កំណត់ហេតុកិច្ចប្រជុំលើកទី ៣ នៃអនុគណៈកម្មការបច្ចេកទេសចម្រុះព្រំដែនកម្ពុជា-ឡាវ និងឡាវ-កម្ពុជា | ទីក្រុងសៀមរាប, ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០២ |

សមស្របតាមច្បាប់អន្តរជាតិ។

**ប្រការ ៦**

សន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋនេះ នឹងត្រូវបានផ្តល់សច្ចាប័ន និងចូលជាធរមាន ចាប់ពីថ្ងៃផ្លាស់ប្តូរលិខិតុបករណ៍សច្ចាប័ន។

ធ្វើនៅវៀងច័ន្ទ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ ជាពីរច្បាប់ដើម ជាបីភាសា គឺភាសាខ្មែរ ភាសាឡាវ និងភាសាបារាំង។ អត្ថបទទាំងបីច្បាប់នេះ មានតម្លៃស្មើគ្នា។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទជាភាសាបារាំងត្រូវយកមកធ្វើជាឯកសារយោង៕

**ក្នុងនាម**
**ព្រះរាជាណាចក្រកម្ពុជា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី**

**ក្នុងនាម**
**សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ**

**សនសាយ ស៊ីផាន់ដន**
**នាយករដ្ឋមន្ត្រី**

២-ធ្វើការផ្លាស់ប្តូរបង្គោលព្រំដែន ដែលបានបោះរួចហើយនៅលើដីជាក់ស្តែង ចំនួន ១២១ បង្គោល ជំនួសដោយបង្គោលថ្មី នៅលើទីតាំងចាស់តាមនិយាមកាដូចមានក្នុងចំណុចទី១ខាងលើ ឲ្យបានរឹងមាំ និងធំជាងមុន តាមគម្រូបង្គោលដែលភាគីទាំងពីរព្រមព្រៀងគ្នា។

៣-សិក្សារួមគ្នាអំពីចំនួនបង្គោលព្រំដែនបំពេញបន្ថែម បង្គោលចំណុចពិសេស រូបរាងបង្គោលព្រំដែន បង្គោលព្រំដែនបំពេញបន្ថែម បង្គោលគម្រុយ និងបង្គោលចំណុចពិសេស និងធ្វើការខណ្ឌសីមា បោះបង្គោលព្រំដែននៅតំបន់ដែលភាគីទាំងពីរបានឯកភាពគ្នា។

៤-ខណ្ឌសីមា និងបោះបង្គោលព្រំដែនរួមគ្នា នៅតំបន់ព្រំដែនដែលភាគីទាំងពីរបានឯកភាពគ្នា។

៥-ផលិតផែនទីឋានលេខាព្រំដែនរដ្ឋ ខ្នាត ១/២៥ ០០០ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដើម្បីភ្ជាប់ជាឧបសម្ព័ន្ធនៃពិធីសារស្តីពីការខណ្ឌសីមា និងបោះបង្គោលព្រំដែនដែលភាគីទាំងពីរសម្រេចបាន។

៦-ធ្វើពិធីសារស្តីពីការខណ្ឌសីមា និងបោះបង្គោលព្រំដែនរវាងប្រទេសទាំងពីរ នៅតំបន់ដែលភាគីទាំងពីរបានឯកភាពគ្នា ដោយបរិយាយលម្អិតអំពីខ្សែព្រំដែន បង្គោលព្រំដែន និងផែនទីឋានលេខាព្រំដែនរវាងប្រទេសទាំងពីរ ដោយបង្ហាញពីទិសដើរនៃខ្សែព្រំដែន និងទីតាំងបង្គោលព្រំដែនដែលស្ថិតនៅតាមបណ្តោយព្រំដែនទាំងមូលរវាងប្រទេសទាំងពីរ ដើម្បីភ្ជាប់ជាឧបសម្ព័ន្ធអមសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋរវាងប្រទេសទាំងពីរ។

ចំពោះរាល់ការចំណាយខាងលើ ភាគីទាំងពីរឯកភាពចេញចំណាយស្មើៗគ្នា។

៧-ខិតខំបន្តពិភាក្សារកដំណោះស្រាយឲ្យបានឆាប់បំផុត កំណាត់ខ្សែព្រំដែនមិនទាន់ឯកភាពគ្នាដូចមានក្នុងប្រការ ៣ តាមគោលការណ៍ទាំង៤ ក្នុងការដោះស្រាយព្រំដែនដែលភាគីទាំងពីរសម្រេចបានកន្លងមក និងដូចមានក្នុងលិខិតរួមរបស់នាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរកម្ពុជា-ឡាវ ឡាវ-កម្ពុជា ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៧ ទៅប្រធានាធិបតីបារាំង រួមនឹងឯកសារទាំងឡាយដែលភាគីទាំងពីរបានព្រមព្រៀងគ្នា។

ពិធីសារស្តីពីការខណ្ឌសីមា និងបោះបង្គោលព្រំដែន គឺជាផ្នែកមួយដែលមិនអាចកាត់ចេញពីសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋនេះបានឡើយ។

គណៈកម្មការចម្រុះព្រំដែននៃប្រទេសទាំងពីរ នឹងចាប់ផ្តើមអនុវត្តការងារដូចមានក្នុងប្រការ ៣ និងប្រការ ៤ ភ្លាម ក្រោយសន្ធិសញ្ញានេះចូលជាធរមាន។

## ប្រការ ៥

ក្នុងករណីមានការខ្វែងគំនិតគ្នាក្នុងការបកស្រាយ ឬការអនុវត្តខុសគ្នាណាមួយទៅនឹងខ្លឹមសារនៃសន្ធិសញ្ញានេះ ភាគីទាំងពីរនឹងដោះស្រាយដោយសន្តិវិធី តាមរយៈការពិគ្រោះពិភាក្សា និងចរចា

ស្តែងរួចហើយនោះ ភាគីទាំងពីរនឹងពិភាក្សាលើការកំណត់កម្មសិទ្ធិកោះ និងដីដុះនោះ ដោយឈរលើមូលដ្ឋានស្មើភាព និងសមស្រប។

១.៣-ក្នុងករណីជួបការលំបាក ក្នុងការអនុវត្តគោលការណ៍ទាំងឡាយខាងលើ ភាគីទាំងពីរនឹងពិភាក្សាគ្នារកដំណោះស្រាយសមស្របមួយ ដែលភាគីទាំងពីរអាចទទួលយកបាន។

## ប្រការ ៣

កំណាត់ខ្សែព្រំដែនដែលមិនទាន់ឯកភាពគ្នាដូចមានក្នុងកំណត់ហេតុ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៩ និងកិច្ចព្រមព្រៀង ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ដោយឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសនៃប្រទេសទាំងពីរ កម្ពុជា-ឡាវ ឡាវ-កម្ពុជា ភាគីទាំងពីរឯកភាពឲ្យគណៈកម្មការចម្រុះព្រំដែននៃប្រទេសទាំងពីរបន្តការពិភាក្សារកដំណោះស្រាយ បន្ទាប់ពីភាគីទាំងពីរចុះហត្ថលេខាលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋរវាងប្រទេសទាំងពីរ។

បញ្ជីកំណាត់ខ្សែព្រំដែន និងបង្គោលព្រំដែនមិនទាន់ឯកភាពទុកបន្តការពិភាក្សា ដោះស្រាយដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ៣ អមសន្ធិសញ្ញានេះ។

កំណាត់ខ្សែព្រំដែនដែលបានចុះត្រួតពិនិត្យរួច និងមិនទាន់ត្រូវបានចុះត្រួតពិនិត្យនៅលើដីជាក់ស្តែងដែលពុំទាន់ឯកភាពគ្នា និងដែលពុំមានបញ្ជាក់ក្នុងចំណុច១.២ នៃប្រការមួយ (១) នៃសន្ធិសញ្ញានេះ ភាគីទាំងពីរនឹងបន្តការពិភាក្សារកដំណោះស្រាយដោយសន្តិវិធី ដោយផ្អែកលើគោលការណ៍ដូចមានចែងក្នុងចំណុច ១.១ ប្រការ១ នៃសន្ធិសញ្ញានេះ និងដូចមានក្នុងសំណើរួមរបស់នាយករដ្ឋមន្ត្រី នៃប្រទេសទាំងពីរ កម្ពុជា-ឡាវ ឡាវ-កម្ពុជា ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៧ ទៅប្រធានាធិបតីបារាំង រួមនឹងឯកសារទាំងឡាយដែលភាគីទាំងពីរបានព្រមព្រៀងគ្នា ដូចមានក្នុងឧបសម្ព័ន្ធ១ អមសន្ធិសញ្ញានេះ។

បញ្ជីកំណាត់ខ្សែព្រំដែនដែលបានចុះត្រួតពិនិត្យរួច និងមិនទាន់ត្រូវបានចុះត្រួតពិនិត្យ ទុកបន្តការពិភាក្សា ដោះស្រាយដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ៤ អមសន្ធិសញ្ញានេះ។

## ប្រការ ៤

ភាគីទាំងពីរឯកភាពឲ្យគណៈកម្មការចម្រុះព្រំដែននៃប្រទេសទាំងពីរ បន្ទាប់ពីចុះហត្ថលេខាលើសន្ធិសញ្ញានេះរួច អនុវត្តការកិច្ចមួយចំនួនដូចខាងក្រោម៖

១-ចុះធ្វើការវាស់វែងនិយាមការឡើងវិញទីតាំងបង្គោលព្រំដែនទាំង១២១ ដែលបានបោះរួចហើយនៅលើដី ដោយប្រើប្រាស់ម៉ាស៊ីន Dual Frequency GPS ដើម្បីធ្វើឲ្យប្រសើរឡើងនិយាមកាទីតាំងបង្គោលព្រំដែនទាំងនោះឲ្យមានភាពជាក់លាក់ខ្ពស់ ដើម្បីបម្រើឲ្យការងារធ្វើពិធីសារស្តីពីការខណ្ឌសីមា និងបោះបង្គោលព្រំដែនរវាងប្រទេសទាំងពីរ។

ទទឹងខាងជើង 107°32'38.437" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 145 ខ្សែព្រំដែនបន្តដើរទៅទិសខាងកើត(បូព៌ា) រហូតដល់បង្គោលចំណុចប្រសព្វបីប្រទេស កម្ពុជា-ឡាវ-វៀតណាម មានទីតាំងស្ថិតនៅលើកំពូលភ្នំ ត្រង់ចំណុចមាននិយាមកាកូមិសាស្ត្រ 14°41'09.800" រយៈទទឹងខាងជើង 107°33' 23.790" រយៈបណ្តោយខាងកើត និងមានរយៈកំពស់ 1081 ម៉ែត្រ។

បញ្ជីតារាងនិយាមកាបោះបង្គោលព្រំដែនចំនួន ១២១ ដូចមានក្នុងឧបសម្ព័ន្ធ ២ អមសន្ធិសញ្ញានេះ។

## ប្រការ ២

១-ភាគីទាំងពីរបានឯកភាពអនុវត្តតាមគោលការណ៍ និងការអនុវត្តជាអន្តរជាតិ ស្តីពីព្រំដែនដើរតាមទន្លេ ឬផ្លូវទឹក ដើម្បីកំណត់ខ្សែព្រំដែនដើរតាមទន្លេ ឬផ្លូវទឹក នៅតាមបណ្តោយព្រំដែនគោកទាំងមូលនៃប្រទេសទាំងពីរដូចខាងក្រោម៖

-ចំពោះកំណាត់ព្រំដែនទឹក ដើរតាមព្រែក ស្ទឹង ដែលមិនអាចធ្វើនាវាចរបាន ខ្សែព្រំដែនត្រូវដើរតាមបន្ទាត់ទ្រូងនៃជ្រលងផ្លូវទឹកនោះ (ដើរតាមពាក់កណ្តាលនៃចន្លោះច្រាំងទាំងពីរ)។

-ចំពោះកំណាត់ព្រំដែនទឹក ដើរតាមព្រែក ស្ទឹង ដែលអាចធ្វើនាវាចរបាន ខ្សែព្រំដែននោះ ត្រូវដើរតាមបន្ទាត់ទ្រូងនៃជ្រលងទឹកជ្រៅ (ដើរតាមកណ្តាលនៃជម្រៅទឹកដែលធ្វើនាវាចរបាន)។

គោលការណ៍ខាងលើត្រូវបានបង្ហាញជាក់ស្តែងដូចខាងក្រោម៖

១.១-ទីតាំងជាក់លាក់របស់បន្ទាត់ទ្រូងនៃផ្លូវទឹកសំខាន់ ឬជ្រលងទឹកជ្រៅ ដែលអាចធ្វើនាវាចរបាន និងកម្មសិទ្ធិកោះ ដីដុះ និងច្រាំងបាក់ ក្នុងផ្លូវទឹក ស្ទឹង ព្រែក ទន្លេ នឹងត្រូវកំណត់ដោយភាគីទាំងពីរក្នុងពេលដំណើរការខណ្ឌសីមា និងបោះបង្គោលព្រំដែន។

លក្ខណៈវិនិច្ឆ័យសំខាន់សម្រាប់ឲ្យនិយមន័យដល់ផ្លូវទឹកសំខាន់ គឺបរិមាណទឹក នៃកំពស់ទឹកមធ្យម។ លក្ខណៈវិនិច្ឆ័យសំខាន់សំរាប់ឲ្យនិយមន័យដល់ជ្រលងទឹកជ្រៅសំខាន់ ដែលអាចធ្វើនាវាចរបាន គឺជម្រៅទឹកនៃជ្រលងទឹកជ្រៅដែលអាចធ្វើនាវាចរបាន។ បន្ទាត់ទ្រូងនៃជ្រលងទឹកជ្រៅសំខាន់ដែលអាចធ្វើនាវាចរបាន គឺជាបន្ទាត់ទ្រូងនៃផ្លូវទឹកដែលស្ថិតនៅចន្លោះខ្សែបន្ទាត់ពីរ ដែលមានជម្រៅទឹកស្មើគ្នា ហើយដែលខ្សែបន្ទាត់ទាំងពីរនេះ ជាខ្សែបន្ទាត់កំណត់ជ្រលងទឹកជ្រៅសំខាន់ដែលអាចធ្វើនាវាចរបាន។

១.២-ក្នុងករណីដែលពុំមានការព្រមព្រៀងរវាងភាគីទាំងពីរទេ ការប្រែប្រួលណាមួយដែលអាចកើតមានឡើងចំពោះផ្លូវទឹក ស្ទឹង ព្រែក យកធ្វើជាខ្សែព្រំដែននោះ ពុំអាចធ្វើឲ្យមានការផ្លាស់ប្តូរដល់ទិសដើររបស់ខ្សែព្រំដែន និងពុំជះឥទ្ធិពលដល់ទ្រង់ទ្រាយនៃខ្សែព្រំដែន ឬដល់កម្មសិទ្ធិនៃកោះ និងដីដុះថ្មីនោះឡើយ។ ចំពោះកោះ និងដីដុះ ដែលទើបនឹងកើតមានឡើងថ្មី ក្នុងផ្លូវទឹកដែលយកធ្វើជាខ្សែព្រំដែន ក្រោយពេលដែលខ្សែព្រំដែននោះត្រូវបានកំណត់នៅលើដីជាក់ស្តែងរួចហើយ កម្មសិទ្ធិកោះ និងដីដុះនោះ នឹងត្រូវកំណត់ទៅតាមខ្សែព្រំដែនដូចបានបញ្ជាក់នៅលើដីជាក់ស្តែង។ ចំពោះកោះ និងដីដុះណា ដែលទើបនឹងកើតមានឡើងថ្មី ហើយស្ថិតនៅលើខ្សែព្រំដែនដែលបានកំណត់នៅលើដីជាក់

ប្រហែល 14°34′58.498″ រយៈទទឹងខាងជើង 107°27′21.058″ រយៈបណ្ដោយខាងកើត ។ ពីបង្គោលលេខ 136 ខ្សែព្រំដែនប្ដូរទិសទៅទិសឦសាន តាមខ្សែបែងចែកទឹក រួចបត់ទៅទិសខាងកើត (បូព៌ា) តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 137 មានទីតាំងស្ថិតនៅលើកំពូលភ្នំ(គ្មានឈ្មោះ) ត្រង់ចំណុចមាននិយាមកាភូមិ- សាស្ត្រប្រហាក់ប្រហែល 14°35′21.000″ រយៈទទឹងខាងជើង 107°28′14.013″ រយៈបណ្ដោយខាងកើត។ ពីបង្គោលលេខ 137 ខ្សែព្រំដែនប្ដូរទិសទៅទិសខាងជើង (ឧត្តរ) ទៅទិសពាយ័ព្យ ទៅទិសឦសាន និងទៅទិសខាងជើង(ឧត្តរ) តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 138 មានទីតាំងស្ថិតនៅលើកំពូលភ្នំ(គ្មានឈ្មោះ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°36′38.247″ រយៈទទឹងខាងជើង 107°28′01.916″ រយៈបណ្ដោយខាងកើត ។ ពីបង្គោលលេខ 138 ខ្សែព្រំដែនប្ដូរទិសទៅទិសឦសានតាមខ្សែបែងចែកទឹក រួចបន្តទៅទិសខាងកើត(បូព៌ា) តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 139 មានទីតាំងស្ថិតនៅលើកំពូលភ្នំ(គ្មានឈ្មោះ)មានរយៈកម្ពស់ 902 ម៉ែត្រ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°37′23.572″ រយៈទទឹងខាងជើង 107°29′19.822″ រយៈបណ្ដោយខាងកើត ។ ពីបង្គោលលេខ 139 ខ្សែព្រំដែនប្ដូរទិសទៅទិសអាគ្នេយ៍ ទៅទិសឦសាន និងទៅទិសពាយ័ព្យតាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 140 មានទីតាំងស្ថិតនៅលើកំពូលភ្នំ(គ្មានឈ្មោះ) មានរយៈកម្ពស់ 843 ម៉ែត្រ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°37′53.517″ រយៈទទឹងខាងជើង 107°30′03.354″ រយៈបណ្ដោយខាងកើត ។ ពីបង្គោលលេខ 140 ខ្សែព្រំដែនប្ដូរទិសទៅទិសឦសាន តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 141 មានទីតាំងស្ថិតនៅលើកំពូលភ្នំ(គ្មានឈ្មោះ)ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°38′20.138″ រយៈទទឹងខាងជើង 107°30′41.105″ រយៈបណ្ដោយខាងកើត ។ ពីបង្គោលលេខ 141 ខ្សែព្រំដែនប្ដូរទិសទៅទិសខាងជើង និងទិសឦសាន តាមខ្សែបែងចែកទឹក កាត់ផ្លូវលំនៅចន្លោះប៉ុស្តិ៍កន្ទុយនាគ(កម្ពុជា) និងប៉ុស្តិ៍ញ៉ាង(ឡាវ) រហូតដល់បង្គោលលេខ 142 មានទីតាំងស្ថិតនៅលើកំពូលភ្នំឈើទាល(ភូញ៉ាង) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°38′48.686″ រយៈទទឹងខាងជើង 107°31′15.005″ រយៈបណ្ដោយខាងកើត ។ ពីបង្គោលលេខ 142 ខ្សែព្រំដែនប្ដូរទិសទៅទិសខាងជើង និងបត់ទៅទិសឦសានតាមខ្សែបែងចែកទឹករហូតដល់បង្គោលលេខ 143 មានទីតាំងស្ថិតនៅលើកំពូលភ្នំ(គ្មានឈ្មោះ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°39′42.449″ រយៈទទឹងខាងជើង 107°31′41.947″ រយៈបណ្ដោយខាងកើត ។ ពីបង្គោលលេខ 143 ខ្សែព្រំដែនប្ដូរទិសទៅទិសខាងជើងតាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 144 មានទីតាំងស្ថិតនៅលើកំពូលភ្នំ(គ្មានឈ្មោះ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°40′50.576″ រយៈទទឹងខាងជើង 107°31′45.938″ រយៈបណ្ដោយខាងកើត ។ ពីបង្គោលលេខ 144 ខ្សែព្រំដែនប្ដូរទិសទៅខាងកើត(បូព៌ា) ទៅទិសឦសាន និងបត់ទៅទិសអាគ្នេយ៍ តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 145 មានទីតាំងស្ថិតនៅលើកំពូលភ្នំ(គ្មានឈ្មោះ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14° 41′08.541″ រយៈ

(បូព៌ា) រួចបត់ទៅទិសអាគ្នេយ៍តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 127 មានទីតាំងស្ថិតនៅលើកំពូលភ្នំ(គ្មានឈ្មោះ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º35'07.419" រយៈទទឹងខាងជើង 107º19'13.561" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 127 ខ្សែព្រំដែនប្តូរទៅខាងកើត(បូព៌ា) តាមខ្សែបែងចែកទឹករួចបត់ទៅទិសអាគ្នេយ៍តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 128 មានទីតាំងស្ថិតនៅលើកំពូលភ្នំ(គ្មានឈ្មោះ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º34'39.358" រយៈទទឹងខាងជើង 107º20'50.131" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 128 ខ្សែព្រំដែនបន្តដើរទៅទិសអាគ្នេយ៍ តាមខ្សែបែងចែកទឹក រួចបត់ចុះមកទិសខាងត្បូង (ទក្សិណ) រហូតដល់បង្គោលលេខ 129 មានទីតាំងស្ថិតនៅលើកំពូលភ្នំ(គ្មានឈ្មោះ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º33'14.574" រយៈទទឹងខាងជើង 107º21'59.435" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 129 ខ្សែព្រំដែនដើរទៅទិសអាគ្នេយ៍ តាមខ្សែបែងចែកទឹក កាត់កំពូលភ្នំមានរយៈកម្ពស់ 977 ម៉ែត្រ រហូតដល់បង្គោលលេខ 130 មានទីតាំងស្ថិតនៅលើកំពូលភ្នំ(គ្មានឈ្មោះ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º32'22.125" រយៈទទឹងខាងជើង 107º22'42.557" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 130 ខ្សែព្រំដែនប្តូរទិសទៅទិសខាងកើត តាមខ្សែបែងចែកទឹក កាត់កំពូលភ្នំមានរយៈកម្ពស់ 943 ម៉ែត្រ រួចបន្តតាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 131 មានទីតាំងស្ថិតនៅលើកំពូលភ្នំ(គ្មានឈ្មោះ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º32'27.509" រយៈទទឹងខាងជើង 107º24'03.797" រយៈបណ្តោយខាងកើត។ ពីបង្គោលលេខ 131 ខ្សែព្រំដែនប្តូរទិសទៅទិសអាគ្នេយ៍ តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 132 មានទីតាំងស្ថិតនៅលើកំពូលភ្នំ(គ្មានឈ្មោះ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º31'38.410" រយៈទទឹងខាងជើង 107º25'27.449" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 132 ខ្សែព្រំដែនបន្តដើរទៅទិសខាងកើត(បូព៌ា) រួចប្តូរទិសទៅទិសនិរតីតាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 133 មានទីតាំងស្ថិតនៅលើកំពូលភ្នំ(គ្មានឈ្មោះ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º31'34.143" រយៈទទឹងខាងជើង 107º27'08.045" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 133 ខ្សែព្រំដែនប្តូរទិសទៅទិសនិរតី ដល់កំពូលភ្នំមានរយៈកម្ពស់ 675 ម៉ែត្រ រួចប្តូរទៅទិសពាយ័ព្យ តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 134 មានទីតាំងស្ថិតនៅលើកំពូលភ្នំ(គ្មានឈ្មោះ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º32'03.799" រយៈទទឹងខាងជើង 107º27'24.267" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 134 ខ្សែព្រំដែនបន្តដើរតាមទិសពាយ័ព្យ រួចប្តូរទិសទៅទិសនិរតី តាមខ្សែបែងចែកទឹករហូតដល់បង្គោលលេខ 135 មានទីតាំងស្ថិតនៅលើកំពូលភ្នំ (គ្មានឈ្មោះ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º33'13.607" រយៈទទឹងខាងជើង 107º27'29.781" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 135 ខ្សែព្រំដែនប្តូរទិសទៅ ទិសខាងជើង និងទៅទិសពាយ័ព្យ តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 136 មានទីតាំងស្ថិតនៅលើកំពូលភ្នំ (គ្មានឈ្មោះ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់

ទិសពាយ័ព្យ ទិសឦសាន តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 117 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 107°08'20.647" រយៈបណ្តោយខាងកើត 14°24'49.972" រយៈទទឹងខាងជើង ។ ពីបង្គោលលេខ 117 ខ្សែព្រំដែនបត់ទៅទិសខាងកើត(បូព៌ា) ហើយបន្តបត់ទៅទិសឦសាន រួចបន្តបត់ទៅទិសខាងកើត និងបែរចុះទៅទិសខាងត្បូង(ទក្សិណ) កាត់ចំណុចមានរយៈកម្ពស់ 1244 ម៉ែត្រ រួចបត់ទៅទិសឦសាន តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 118 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°25'17.435" រយៈទទឹងខាងជើង 107°10'38.842" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 118 ខ្សែព្រំដែនបន្តដើរទៅទិសខាងជើង(ឧត្តរ) តាមខ្សែបែងចែកទឹក រួចបន្តទៅទិសខាងកើត(បូព៌ា) ហើយបន្តទៅទិសឦសាន រហូតដល់បង្គោលលេខ 119 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°26'34.466" រយៈទទឹងខាងជើង 107°11'52.836" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 119 ខ្សែព្រំដែនដើរទៅទិសខាងជើង(ឧត្តរ)តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 120 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°28'31.153" រយៈទទឹងខាងជើង 107°12'17.556" រយៈបណ្តោយខាងកើត។ ពីបង្គោលលេខ 120 ខ្សែព្រំដែនដើរទៅទិសឦសានតាមខ្សែបែងចែកទឹក រួចបត់ទៅទិសពាយ័ព្យ ហើយបន្ទាប់មកបត់តាមទិសខាងកើត (បូព៌ា) រហូតដល់បង្គោលលេខ 121 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°29'13.730" រយៈទទឹងខាងជើង 107°13'10.099" រយៈបណ្តោយខាងកើត ចំណុចមានរយៈកម្ពស់ 704 ម៉ែត្រ ។ ពីបង្គោលលេខ 121 ខ្សែព្រំដែនបន្តដើរទៅទិសខាងកើត(បូព៌ា)តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 122 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°28'42.731" រយៈទទឹងខាងជើង 107°14'38.872" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 122 ខ្សែព្រំដែនបន្តទៅទិសឦសានតាមខ្សែបែងចែកទឹក កាត់ចំណុចមានរយៈកម្ពស់ 690 ម៉ែត្រ ហើយបត់ទៅទិសខាងជើង(ឧត្តរ) រហូតដល់បង្គោលលេខ 123 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°30'31.158" រយៈទទឹងខាងជើង 107°15'26.079" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 123 ខ្សែព្រំដែនបន្តទៅទិសខាងជើង(ឧត្តរ) តាមខ្សែបែងចែកទឹកកាត់ចំណុចមានរយៈកម្ពស់ 832 ម៉ែត្រ រហូតដល់បង្គោលលេខ 124 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 107°15'53.885" រយៈបណ្តោយខាងកើត 14°32'28.226" រយៈទទឹងខាងជើង ។ ពីបង្គោលលេខ 124 ខ្សែព្រំដែនបត់ទៅទិសខាងកើត(បូព៌ា) រួចបន្តបត់ទៅទិសឦសាន តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 125 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°33'25.368" រយៈទទឹងខាងជើង 107°17'22.142" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 125 ខ្សែព្រំដែនដើរតាមទិសរួមឆ្ពោះទៅទិសខាងជើង(ឧត្តរ) រួចបត់ទៅទិសខាងកើត(បូព៌ា) រួចបន្តឡើងទៅទិសខាងជើង (ឧត្តរ) តាមខ្សែបែងចែកទឹករហូតដល់បង្គោលលេខ 126 មានទីតាំងស្ថិតនៅលើកំពូលភ្នំ(គ្មានឈ្មោះ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°34'46.569" រយៈទទឹងខាងជើង 107°17'28.091" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 126 ខ្សែព្រំដែនប្តូរទិសទៅទិសខាងកើត

ដើរទៅទិសអាគ្នេយ៍ តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 106 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°18'45.275" រយៈទទឹងខាងជើង 106°57'00.487" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 106 ខ្សែព្រំដែនដើរទៅទិសខាងកើត(បូព៌ា) តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 107 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°18'44.570" រយៈទទឹងខាងជើង 106°58'18.097" រយៈបណ្តោយខាងកើត ចំណុចមានរយៈកម្ពស់ 1010 ម៉ែត្រ ។ ពីបង្គោលលេខ 107 ខ្សែព្រំដែនបន្តដើរទៅទិសឦសានតាមខ្សែបែងចែកទឹក កាត់ចំណុចមានរយៈកម្ពស់ 1047 ម៉ែត្រ ហើយដើរតាមទិសឦសាន រួចបត់ទៅទិសពាយ័ព្យ រហូតដល់បង្គោលលេខ 108 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°20'21.184" រយៈទទឹងខាងជើង 106°58'28.052" រយៈបណ្តោយខាងកើត។ ពីបង្គោលលេខ 108 ខ្សែព្រំដែនបន្តដើរទៅទិសខាងជើង(ឧត្តរ) តាមខ្សែបែងចែកទឹកដល់បង្គោលលេខ 109 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°21'26.045" រយៈទទឹងខាងជើង 106°58'49.413" រយៈបណ្តោយខាងកើត ចំណុចមានរយៈកម្ពស់ 1455 ម៉ែត្រ ។ ពីបង្គោលលេខ 109 ខ្សែព្រំដែនបន្តទៅទិសខាងកើត(បូព៌ា) រួចប្តូរទៅទិសខាងជើង(ឧត្តរ) តាមខ្សែបែងចែកទឹក កាត់ចំណុចមានរយៈកម្ពស់ 1065 ម៉ែត្រ រហូតដល់បង្គោលលេខ 110 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°22'24.332" រយៈទទឹងខាងជើង 107°00'27.956" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 110 ខ្សែព្រំដែនបន្តដើរទៅទិសឦសានតាមខ្សែបែងចែកទឹក ដល់បង្គោលលេខ 111 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°24'05.177" រយៈទទឹងខាងជើង 107°01'34.352" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 111 ខ្សែព្រំដែនបន្តដើរទៅទិសឦសាន តាមខ្សែបែងចែកទឹក ដល់បង្គោលលេខ 112 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°24'50.303" រយៈទទឹងខាងជើង 107°03'01.054" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 112 ខ្សែព្រំដែនប្តូរទិសឡើងទៅទិសខាងជើង(ឧត្តរ) តាមខ្សែបែងចែកទឹក កាត់ចំណុចមានរយៈកម្ពស់ 1351 ម៉ែត្រ និង 1487 ម៉ែត្រ ហើយបត់ទៅតាមទិសឦសាន រហូតដល់បង្គោលលេខ 113 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°26'51.710" រយៈទទឹងខាងជើង 107°02'47.408" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 113 ខ្សែព្រំដែនបន្តដើរតាមខ្សែបែងចែកទឹកទៅទិសអាគ្នេយ៍ រហូតដល់បង្គោលលេខ 114 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°25'30.356" រយៈទទឹងខាងជើង 107°04'55.793" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 114 ខ្សែព្រំដែនបត់ចុះទៅទិសខាងត្បូង កាត់ចំណុចមានរយៈកម្ពស់ 1018 ម៉ែត្រ តាមខ្សែបែងចែកទឹករហូតដល់បង្គោលលេខ 115 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 107°05'13.692" រយៈបណ្តោយខាងកើត 14°23'39.681" រយៈទទឹងខាងជើង ។ ពីបង្គោលលេខ 115 ខ្សែព្រំដែនដើរទៅទិសខាងកើត(បូព៌ា) តាមខ្សែបែងចែកទឹកកាត់ចំណុចមានរយៈកម្ពស់ 1214 ម៉ែត្រ រហូតដល់បង្គោលលេខ 116 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°23'43.894" រយៈទទឹងខាងជើង 107°07'30.650" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 116 ខ្សែព្រំដែនដើរទៅ

មានចម្ងាយ 24 ម៉ែត្រពីខ្សែព្រំដែន។ បង្គោល L-077 ស្ថិតនៅត្រើយខាងឆ្វេងអូរឬស្សី(អូរកុក) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°26'22.247" រយៈទទឹងខាងជើង 106°19'09.415" រយៈបណ្តោយខាងកើត មានចម្ងាយ 18 ម៉ែត្រ ពីខ្សែព្រំដែន។ ពីទីតាំងបង្គោលលេខ 077 ខ្សែព្រំដែនដើរទៅទិសខាងកើតតាមពាក់កណ្តាលអូរឬស្សី(អូរកុក) រហូតមកដល់ទីតាំងបង្គោលគ្លោះលេខ 078 ស្ថិតនៅទាំងសងខាងមាត់ពាមរវាងអូរឬស្សី(អូរកុក)និងទន្លេសេកុង ។ បង្គោល C-078 ស្ថិតនៅត្រើយខាងស្តាំ(ខាងត្បូង) អូរឬស្សី(អូរកុក) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°26'10.465" រយៈទទឹងខាងជើង 106°20'01.612" រយៈបណ្តោយខាងកើត មានចម្ងាយ 28 ម៉ែត្រ ពីខ្សែព្រំដែន។ បង្គោល L-078 ស្ថិតនៅត្រើយខាងឆ្វេងអូរឬស្សី(អូរកុក) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°26'10.465" រយៈទទឹងខាងជើង 106°20'01.612" រយៈបណ្តោយខាងកើត មានចម្ងាយ 32 ម៉ែត្រ ពីខ្សែព្រំដែន។

បង្គោលលេខ 099 មានទីតាំងស្ថិតនៅលើកំពូលភ្នំ ត្រង់ចំណុចជួរកំពូលភ្នំបែក ភ្នំហាឡឹង(ឡាវ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°19'09.895" រយៈទទឹងខាងជើង 106°48'27.679" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 099 ខ្សែព្រំដែនដើរឆ្ពោះទៅទិសអាគ្នេយ៍តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 100 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°18'18.651" រយៈទទឹងខាងជើង 106°50'25.767" រយៈបណ្តោយខាងកើត និងចំណុចមានរយៈកម្ពស់ 826 ម៉ែត្រ ។ ពីបង្គោលលេខ 100 ខ្សែព្រំដែនបត់ចុះទៅទិសខាងត្បូង(ទក្សិណ) រួចបត់ទៅទិសខាងកើត(បូព៌ា)តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 101 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 106°51'19.610" រយៈបណ្តោយខាងកើត 14°17'35.933" រយៈទទឹងខាងជើង។ ពីបង្គោលលេខ 101 ខ្សែព្រំដែនបន្តទៅទិសឦសាន តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 102 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°19'00.582" រយៈទទឹងខាងជើង 106°52'32.020" រយៈបណ្តោយខាងកើត និងចំណុចមានរយៈកម្ពស់ 876 ម៉ែត្រ ។ ពីបង្គោលលេខ 102 ខ្សែព្រំដែនដើរទៅទិសខាងកើត(បូព៌ា)តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 103 មានទីតាំងស្ថិតនៅលើខ្នងភ្នំ(គ្មានឈ្មោះ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°18'44.620" រយៈទទឹងខាងជើង 106°53'39.896" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 103 ខ្សែព្រំដែនប្តូរទិសទៅទិសខាងជើង(ឧត្តរ)តាមខ្សែបែងចែកទឹក កាត់អូរគ្មានឈ្មោះ ហើយបន្តដើរតាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 104 មានទីតាំងស្ថិតនៅលើកំពូលភ្នំ(គ្មានឈ្មោះ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°19'56.827" រយៈទទឹងខាងជើង 106°53'30.924" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 104 ខ្សែព្រំដែនប្តូរទិសទៅទិសខាងកើត(បូព៌ា)តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 105 មានទីតាំងស្ថិតនៅលើកំពូលភ្នំ(គ្មានឈ្មោះ) និងចំណុចកម្ពស់ 701 ម៉ែត្រ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14°19'49.725" រយៈទទឹងខាងជើង 106°54'49.190" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 105 ខ្សែព្រំដែនបន្ត

ចុះទៅទិសឦសានកាត់អូរការលៀង(អូរជាងហៀង) រហូតដល់បង្គោលលេខ 068 មានទីតាំងស្ថិតនៅមាត់អូរខាងឆ្វេងតាមចរន្តទឹកហូរ នៃអូរការលៀង(អូរជាងហៀង) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º22'51.139" រយៈទទឹងខាងជើង 106º13'46.670" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 068 ខ្សែព្រំដែនដើរតាមខ្នងភ្នំឡើងទៅទិសជើង(ឧត្តរ)ជាបន្តទៀត រហូតដល់បង្គោលលេខ 069 មានទីតាំងស្ថិតនៅលើកំពូលភ្នំ មានរយៈកម្ពស់ 184ម៉ែត្រ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º24'41.422" រយៈទទឹងខាងជើង 106º14'33.358" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 069 ខ្សែព្រំដែនដើរទៅទិសខាងជើង រហូតដល់កូនភ្នំ បត់ទៅទិសឦសានតាមខ្នងភ្នំ រហូតដល់បង្គោលលេខ 070 មានទីតាំងស្ថិតនៅលើភ្នំអត់ឈ្មោះ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º26'41.152" រយៈទទឹងខាងជើង 106º15'17.641" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 070 ខ្សែព្រំដែនបន្តបត់ទៅទិសពាយ័ព្យតាមខ្នងភ្នំ រហូតដល់បង្គោលលេខ 071 មានទីតាំងស្ថិតនៅលើកំពូលភ្នំគ្មានឈ្មោះ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º27'37.217" រយៈទទឹងខាងជើង 106º14'43.084" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 071 ខ្សែព្រំដែនបន្តដើរទៅទិសឦសានតាមខ្នងភ្នំ រួចបន្តកាត់ខ្នងភ្នំ មានមានរយៈកម្ពស់ 369 ម៉ែត្រ បត់ទៅទិសខាងកើតតាមខ្នងភ្នំ រហូតដល់បង្គោលលេខ 072 មានទីតាំងស្ថិតនៅលើកំពូលភ្នំអត់ឈ្មោះ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º29'01.631" រយៈទទឹងខាងជើង 106º15'45.955" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 072 ខ្សែព្រំដែនបន្តដើរទៅទិសអាគ្នេយ៍តាមខ្នងភ្នំ បត់ទៅខាងកើត(បូព៌ា)បន្តិច រហូតដល់ បង្គោលលេខ 073 មានទីតាំងស្ថិតនៅលើកំពូលភ្នំគ្មានឈ្មោះមានរយៈកម្ពស់ 367 ម៉ែត្រ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º28'14.241" រយៈទទឹងខាងជើង 106º16'16.785" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 073 ខ្សែព្រំដែនដើរទៅទិសខាងជើង(ឧត្តរ) រួចបត់មកទិសកើត(បូព៌ា)តាមខ្នងភ្នំ រហូតដល់បង្គោលលេខ 074 មានទីតាំងស្ថិតនៅលើកំពូលភ្នំដី(ឌិន) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º27'57.115" រយៈទទឹងខាងជើង 106º17'53.419" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 074 ខ្សែព្រំដែនដើរចុះតាមខ្នងភ្នំមកទិសខាងត្បូង(ទក្សិណ) រហូតដល់បង្គោលលេខ 075 មានទីតាំងស្ថិតនៅលើភ្នំដី(ឌិន) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º26'58.746" រយៈទទឹងខាងជើង 106º18'08.043" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 075 ខ្សែព្រំដែនបត់តាមទិសខាងកើត(បូព៌ា)តាមខ្នងភ្នំនោះរហូតដល់បង្គោលលេខ 076 មានទីតាំងស្ថិតនៅលើភ្នំដី(ឌិន) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º26'51.460" រយៈទទឹងខាងជើង 106º18'54.191" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 076 ខ្សែព្រំដែនដើរចុះមកទិសអាគ្នេយ៍តាមខ្នងភ្នំ រហូតមកដល់ចំណុចកណ្តាលអូរឫស្សី(អូរកុក)ដល់ទីតាំងបង្គោលភ្លោះលេខ 077 ស្ថិតនៅទាំងសងខាងមាត់អូរឫស្សី(អូរកុក)។ បង្គោល C-077 ស្ថិតនៅត្រើយខាងស្តាំអូរឫស្សី(អូរកុក) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º26'21.112" រយៈទទឹងខាងជើង 106º19'08.607" រយៈបណ្តោយខាងកើត

ខាងកើត ។ ពីបង្គោលលេខ 059/1 ខ្សែព្រំដែនដើរទៅទិសខាងជើង(ឧត្តរ)កាត់អូរកំព្រា(ខាំផា) ដល់បង្គោលលេខ 059/2 មានទីតាំងស្ថិតនៅខាងឆ្វេងមាត់ច្រាំងអូរកំព្រា(ខាំផា)ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º21'17.007" រយៈទទឹងខាងជើង 106º05'29.998" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 059/2 ខ្សែព្រំដែនបន្តទៅទិសខាងជើង(ឧត្តរ)តាមខ្នងភ្នំ រហូតដល់បង្គោលលេខ 060 មានទីតាំងស្ថិតនៅលើកំពូលភ្នំទឹកដាំ(ណាំខាំ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 106º05'31.898" រយៈទទឹងខាងជើង 14º21'50.750" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 060 ខ្សែព្រំដែនដើរទៅទិសពាយ័ព្យ រហូតដល់បង្គោលលេខ 061 មានទីតាំងស្ថិតនៅលើកំពូលភ្នំឡែ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º22'24.734" រយៈទទឹងខាងជើង 106º06'27.089" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 061 ខ្សែព្រំដែនបន្តបត់ទៅទិសអាគ្នេយ៍តាមខ្នងភ្នំរហូតដល់បង្គោលលេខ 062 មានទីតាំងស្ថិតនៅលើភ្នំប៉ាអេម ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º21'19.492" រយៈទទឹងខាងជើង 106º07'32.775" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 062 ខ្សែព្រំដែនដើរទៅទិសពាយ័ព្យ បន្តដើរតាមខ្នងភ្នំ ចុះកាត់អូរឡែ រហូតដល់បង្គោលលេខ 063 មានទីតាំងស្ថិតនៅខាងឆ្វេងមាត់អូរឡែ(តាមចរន្តទឹកហូរ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º21'40.018" រយៈទទឹងខាងជើង 106º08'02.426" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 063 ខ្សែព្រំដែនដើរទៅទិសពាយ័ព្យ កាត់កំពូលភ្នំ រួចចុះកាត់អូរគ្មានឈ្មោះបន្តដើរឡើងតាមខ្នងភ្នំ រហូតដល់បង្គោលលេខ 064 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º22'11.958" រយៈទទឹងខាងជើង 106º08'54.106" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 064 ខ្សែព្រំដែនបត់ទៅទិសអាគ្នេយ៍ដើរតាមខ្នងភ្នំ រហូតដល់បង្គោលលេខ 065 មានទីតាំងស្ថិតនៅខាងស្តាំមាត់អូរលឹម(តាមចរន្តទឹកហូរ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º21'03.631" រយៈទទឹងខាងជើង 106º10'03.033" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 065 ខ្សែព្រំដែនបន្តដើរទៅទិសខាងកើត(បូព៌ា) ចុះកាត់អូរលឹមឡើងកាត់ខ្នងភ្នំ ចុះកាត់អូរឡានរួចឡើងកាត់កំពូលភ្នំ ដែលមានរយៈកម្ពស់ 144 ម៉ែត្រ ហើយកាត់អូរជំ បន្តឡើងកាត់កំពូលភ្នំ រួចចុះដល់បង្គោលលេខ 066/1 មានទីតាំងស្ថិតនៅខាងស្តាំមាត់ច្រាំងអូរក្តួច(អូរកេយ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º20'54.023" រយៈទទឹងខាងជើង 14º00'41.230" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 066/1 ខ្សែព្រំដែនដើរទៅទិសពាយ័ព្យ កាត់អូរក្តួច(អូរកេយ) រហូតដល់បង្គោលលេខ 066/2 មានទីតាំងស្ថិតនៅខាងឆ្វេងមាត់ច្រាំងអូរក្តួច(អូរកេយ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º20'53.952" រយៈទទឹងខាងជើង 106º11'30.486" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 066/2 ខ្សែព្រំដែនបន្តដើរកាត់អូរខ្សាច់រួចឡើងតាមខ្នងភ្នំទៅទិសពាយ័ព្យ រហូតដល់បង្គោលលេខ 067 មានទីតាំងស្ថិតនៅលើកំពូលភ្នំគ្មានឈ្មោះ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º22'13.845" រយៈទទឹងខាងជើង 106º12'30.207" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 067 ខ្សែព្រំដែនបន្តបត់ចុះមកទិសអាគ្នេយ៍តាមខ្នងភ្នំ ហើយបត់

បង្គោលលេខ 050 មានទីតាំងស្ថិតនៅចំកំពូលភ្នំលេខ 227 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º16'32.872" រយៈទទឹងខាងជើង 106º02'11.374" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 050 ខ្សែព្រំដែនដើរឆ្ពោះទៅទិសខាងជើង(ឧត្តរ) បន្តឡើងតាមខ្សែបែងចែកទឹកនៃជួរកំពូលភ្នំទឹកជាំ រហូតដល់បង្គោលលេខ 051 មានទីតាំងស្ថិតនៅលើកំពូលភ្នំទៀង(កម្ពស់406) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º18'45.794" រយៈទទឹងខាងជើង 106º01'20.075" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 051 ខ្សែព្រំដែនដើរទៅទិសខាងលិច(បស្ចិម) រួចបត់ទៅទិសខាងជើង តាមខ្សែបែងចែកទឹកនៃកំពូលភ្នំតាពូងតូច(ណាំខាំចាក) រហូតដល់បង្គោលលេខ 052 ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º18'59.412" រយៈទទឹងខាងជើង 106º00'23.854" រយៈបណ្តោយខាងកើត។ ពីបង្គោលលេខ 052 ខ្សែព្រំដែនបន្តទៅទិសខាងជើង(ឧត្តរ)តាមខ្សែបែងចែកទឹកនៃជួរកំពូលភ្នំនោះ រហូតដល់បង្គោលលេខ 053 មានទីតាំងស្ថិតនៅលើកំពូលភ្នំត្រងោ(ឡូន) កម្ពស់ 468 ម៉ែត្រ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º20'26.206" រយៈទទឹងខាងជើង 106º00'19.266" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 053 ខ្សែព្រំដែនបន្តដើរទៅទិសពាយ័ព្យតាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 054 មានទីតាំងស្ថិតនៅលើភ្នំគ្មានឈ្មោះ(កម្ពុជា) ភ្នំកាតូក(ឡាវ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º20'52.594" រយៈទទឹងខាងជើង 105º59'58.283" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 054 ខ្សែព្រំដែនដើរឆ្ពោះទៅទិសខាងជើង(ឧត្តរ)តាមខ្សែបែងចែកទឹកនៃជួរភ្នំចាំងកែ(ទៀងកែ) រហូតដល់បង្គោលលេខ 055 មានទីតាំងស្ថិតនៅលើភ្នំចាំងកែ កម្ពស់ 638 ម៉ែត្រ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º22'11.820" រយៈទទឹងខាងជើង 106º00'20.606" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 055 ខ្សែព្រំដែនប្តូរទិសទៅទិសអាគ្នេយ៍តាមខ្សែបែងចែកទឹកនៃជួរកំពូលភ្នំនោះរហូតដល់បង្គោលលេខ 056 មានទីតាំងស្ថិតនៅលើកំពូលភ្នំត្បូងថ្មកែវ(កែវនិន) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º20'31.906" រយៈទទឹងខាងជើង 106º02'19.148" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 056 ខ្សែព្រំដែនដើរឆ្ពោះទៅទិសខាងកើត(បូព៌ា)តាមខ្សែបែងចែកទឹក រហូតដល់បង្គោលលេខ 057 មានទីតាំងស្ថិតនៅលើកំពូលភ្នំណាមតៅ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º20'27.580" រយៈទទឹងខាងជើង 106º03'46.665" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 057 ខ្សែព្រំដែនបត់ទៅទិសខាងជើង(ឧត្តរ) ហើយបត់ទៅទិសខាងកើត(បូព៌ា) រួចបត់ចុះមកទិសអាគ្នេយ៍ តាមខ្សែបែងចែកទឹករហូតដល់បង្គោលលេខ 058 មានទីតាំងស្ថិតនៅលើកំពូលភ្នំកម្ពស់ 252ម៉ែត្រ(ប៉ាកាំង)ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º20'04.946" រយៈទទឹងខាងជើង 106º05'01.573" រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 058 ខ្សែព្រំដែនដើរឆ្ពោះទៅទិសខាងជើង(ឧត្តរ)តាមខ្នងភ្នំ ចុះដល់បង្គោលលេខ 059/1 មានទីតាំងស្ថិតនៅខាងស្តាំមាត់ច្រាំងអូរកំព្រា(ខាំផា) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º 21'15.056" រយៈទទឹងខាងជើង 106º05'29.488" រយៈបណ្តោយ

រយៈទទឹងខាងជើង 106º06′26.594″ រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 036 ខ្សែព្រំដែនដើរទៅទិសពាយ័ព្យ ដល់បង្គោលលេខ 037 មានទីតាំងស្ថិតនៅក្បែរអូរវាល(ហាងជើន) ជិតភូមិស្រែចំប៉ា ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º00′55.790″ រយៈទទឹងខាងជើង 106º08′35.613″ រយៈបណ្តោយខាងកើត ។

បង្គោលលេខ 041 មានទីតាំងស្ថិតនៅក្នុងព្រៃប្រាំបីលាន(ប៉ែតលាន) ខាងត្បូងផ្លូវលំកាត់ខ្សែព្រំដែន ចំណុចប្រសព្វផ្លូវលំទៅភូមិស្រែសំពោង(កម្ពុជា) និងភូមិយីណាក់(ឡាវ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º05′54.019″ រយៈទទឹងខាងជើង 106º08′23.488″ រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 041 ខ្សែព្រំដែនដើរទៅទិសពាយ័ព្យ ដល់បង្គោលលេខ 042 មានទីតាំងស្ថិតនៅខាងកើតក្បាលអូរជែកកេះ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º07′55.371″ រយៈទទឹងខាងជើង 106º07′04.442″ រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 042 ខ្សែព្រំដែនដើរទៅទិសខាងជើង(ឧត្តរ) ដល់បង្គោលលេខ 043 មានទីតាំងស្ថិតនៅក្បាលអូរឈើទាលធំ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º09′08.188″ រយៈទទឹងខាងជើង 106º06′55.991″ រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 043 ខ្សែព្រំដែនដើរទៅទិសខាងជើង(ឧត្តរ) ដល់បង្គោលលេខ 044 មានទីតាំងស្ថិតនៅក្នុងព្រៃក្រវ៉ាន់ធំ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º11′06.327″ រយៈទទឹងខាងជើង 106º06′44.091″ រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 044 ខ្សែព្រំដែនដើរទៅទិសខាងលិច(បស្ចិម) ដល់បង្គោលលេខ 045 មានទីតាំងស្ថិតនៅក្នុងក្បាលអូរថ្មសំលាងកាំបិត ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º11′24.637″ រយៈទទឹងខាងជើង 106º04′53.516″ រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 045 ខ្សែព្រំដែនដើរទៅទិសពាយ័ព្យ ដល់បង្គោលលេខ 046 មានទីតាំងស្ថិតនៅក្បែរផ្លូវលំកាត់ខ្សែព្រំដែន(ផ្លូវបឹងក្តួច) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º12′27.384″ រយៈទទឹងខាងជើង 106º03′20.122″ រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 046 ខ្សែព្រំដែនដើរទៅទិសពាយ័ព្យ ដល់បង្គោលលេខ 047 មានទីតាំងស្ថិតនៅខាងជើងផ្លូវបំបែកទៅ ភូមិគោកសម្បត្តិ និងបឹងក្តួច ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º13′32.508″ រយៈទទឹងខាងជើង 106º02′21.929″ រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 047 ខ្សែព្រំដែនដើរទៅទិសពាយ័ព្យ ដល់បង្គោលលេខ 048 មានទីតាំងស្ថិតនៅក្បែរជើងភ្នំគោ(ក្បែរផ្លូវលំកាត់ខ្សែព្រំដែន) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º14′40.304″ រយៈទទឹងខាងជើង 106º01′52.505″ រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 048 ខ្សែព្រំដែនដើរទៅទិសខាងជើង(ឧត្តរ) តាមខ្នងភ្នំគោ(ភូង្វ) រហូតដល់បង្គោលលេខ 049 មានទីតាំងស្ថិតនៅលើកំពូលភ្នំគោ(ភូង្វ)ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 14º15′33.474″ រយៈទទឹងខាងជើង 106º01′48.175″ រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 049 ខ្សែព្រំដែនដើរឆ្ពោះទៅទិសពាយ័ព្យ រួចបត់ទៅទិសខាងជើង(ឧត្តរ) កាត់ចំណុចប្រសព្វវាងអូរល្អក់ និងអូរថាបសាងហើយឡើងតាមខ្នងភ្នំទឹកជាំ(ណាមខាំ) រហូតដល់

កើត 13°55′36.536″ រយៈទទឹងខាងជើង ។ ពីបង្គោលលេខ 032/9 ខ្សែព្រំដែនបន្តដើរទៅទិសអាគ្នេយ៍ តាមខ្នងទួល រហូតដល់បង្គោលលេខ 032/10 មានទីតាំងស្ថិតនៅលើខ្នងទួល ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 13°55′32.334″ រយៈទទឹងខាងជើង 106°01′06.033″ រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 032/10 ខ្សែព្រំដែនបន្តដើរទៅទិសអាគ្នេយ៍ តាមខ្នងទួលរហូតដល់បង្គោលលេខ 032/11 មានទីតាំងស្ថិតនៅលើខ្នងទួល ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 106°01′09.158″ រយៈបណ្តោយខាងកើត 13°55′30.628″ រយៈទទឹងខាងជើង ។ ពីបង្គោលលេខ 032/11 ខ្សែព្រំដែនបន្តដើរទៅទិសអាគ្នេយ៍តាមខ្នងទួល រហូតដល់បង្គោលលេខ 032/12 មានទីតាំងស្ថិតនៅលើខ្នងទួល ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 13°55′31.636″ រយៈទទឹងខាងជើង 106°01′17.127″ រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 032/12 ខ្សែព្រំដែនបន្តដើរទៅទិសខាងកើត(បូព៌ា)តាមខ្នងទួល រហូតដល់បង្គោលលេខ 032/13 មានទីតាំងស្ថិតនៅលើខ្នងទួល ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 13°55′24.988″ រយៈទទឹងខាងជើង 106° 01′26.962″ រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 032/13 ខ្សែព្រំដែនបន្តដើរទៅទិសអាគ្នេយ៍តាមខ្នងទួល រហូតដល់បង្គោលលេខ 032/14 មានទីតាំងស្ថិតនៅលើខ្នងទួល ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 106°01′36.114″ រយៈបណ្តោយខាងកើត 13°55′22.020″ រយៈទទឹងខាងជើង ។ ពីបង្គោលលេខ 032/14 ខ្សែព្រំដែនបន្តដើរទៅទិសខាងកើត(បូព៌ា) តាមខ្នងទួលរហូតដល់បង្គោលលេខ 032/15 មានទីតាំងស្ថិតនៅលើខ្នងទួល ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 13°55′22.344″ រយៈទទឹងខាងជើង 106°01′44.046″ រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 032/15 ខ្សែព្រំដែនប្តូរទៅទិសខាងកើត(បូព៌ា) តាមខ្នងខ្ពង់រាប រហូតដល់បង្គោលលេខ 032/16 មានទីតាំងស្ថិតនៅលើខ្នងខ្ពង់រាប ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 106°01′48.21″ រយៈបណ្តោយខាងកើត 13°55′21.871″ រយៈទទឹងខាងជើង ។ ពីបង្គោលលេខ 032/16 ខ្សែព្រំដែនបន្តដើរទៅទិសខាងកើត(បូព៌ា) តាមខ្នងខ្ពង់រាប រហូតដល់បង្គោលលេខ 032/17 មានទីតាំងស្ថិតនៅលើខ្នងខ្ពង់រាប ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 13°55′20.216″ រយៈទទឹងខាងជើង 106°01′54.734″ រយៈបណ្តោយខាងកើត ។

បង្គោលលេខ 034 មានទីតាំងស្ថិតនៅលើផ្លូវបែកជាបី ជិតត្រពាំងបួនជ្រុង ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 13°55′01.489″ រយៈទទឹងខាងជើង 106°06′38.702″ រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 034 ខ្សែព្រំដែនដើរទៅទិសខាងជើង(ឧត្តរ) ដល់បង្គោលលេខ 035 មានទីតាំងស្ថិតនៅក្បែរផ្លូវទិសខាងជើងរវាងភូមិសំពោង(សៀមហ្វាង) និងស្រែរមាំ(ណាអួង) កម្ពុជា និងទៅណងលុម(ត្រពាំងកក់) ឡាវ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 13°57′44.761″ រយៈទទឹងខាងជើង 106°06′22.651″ រយៈបណ្តោយខាងកើត ។ ពីបង្គោលលេខ 035 ខ្សែព្រំដែនដើរទៅទិសខាងជើង(ឧត្តរ) ដល់បង្គោលលេខ 036 មានទីតាំងស្ថិតក្នុងតំបន់ទួលស្រែត្រពាំងបែកចាន(ណងស៊ីចេ) ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រប្រហាក់ប្រហែល 13°59′31.307″

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/ ១០១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

ចំពោះ

លោក **អ៊ឹម មូលី**

ចរស. ម៉អ០១. ១០១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រី ប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/១០៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ដំឡើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** នាយទាហានថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ១៦រូបៈ

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ឯក | **លី** | **អ៊ាឌី** | អត្តលេខ ០៤៨៤២៨ |
| ២-វរសេនីយ៍ឯក | **ហុង** | **ចិន្តា** | អត្តលេខ ១៤២០២១ |
| ៣-វរសេនីយ៍ឯក | **ឡាយ** | **ម៉ិនហុង** | អត្តលេខ ១៧៨៩៨០ |
| ៤-វរសេនីយ៍ឯក | **អ៊ុច** | **ច័ន្ទធីរៈ** | អត្តលេខ ០១៤២៤៨ |
| ៥-វរសេនីយ៍ឯក | **សំ** | **សិទ្ធិគុណា** | អត្តលេខ ០២២៣៥៨ |
| ៦-វរសេនីយ៍ឯក | **អៀម** | **ទិបុល** | អត្តលេខ ០២៥០៧១ |
| ៧-វរសេនីយ៍ឯក | **ខៀវ** | **ខេមរិន្ទ** | អត្តលេខ ០០១៦៥០ |
| ៨-វរសេនីយ៍ឯក | **ឡេង** | **សំអុល** | អត្តលេខ ០១០៩៣២ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៩-វរសេនីយ៍ឯក **សេង គីម្សៀ** អត្តលេខ ០៥៩៥៥៥

១០-វរសេនីយ៍ឯក **ហាត់ លីម៉ា** អត្តលេខ ០២០៤៦៨

១១-វរសេនីយ៍ឯក **គង់ គុណ** អត្តលេខ ០៤៣៤៣០

១២-វរសេនីយ៍ឯក **ម៉ឺន ផុន** អត្តលេខ ០៤៣៤៣៩

១៣-វរសេនីយ៍ឯក **ជួន គីមផុន** អត្តលេខ ០០១៦៣២

១៤-វរសេនីយ៍ឯក **ស្រី ផុន** អត្តលេខ ០១៧១៣០

១៥-វរសេនីយ៍ឯក **ទិចិត្រ សម្បត្តិបញ្ញា** អត្តលេខ ០៤២៩៦៩

១៦-វរសេនីយ៍ឯក **អ៊ុង ធីរៈ** អត្តលេខ ២១០២៦១

**មាត្រា២៖** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នរោត្តម សីហមុនី

នស.រកត.០១២៣.១០៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/ ១០៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រី ដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំង និងផ្តល់ឋានៈ ឯកឧត្តម **ប៊ី បញ្ញាសិទ្ធ** ជាទីប្រឹក្សាសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក ដោយពុំទទួលប្រាក់បំណាច់មុខងារ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៧៩៤. ២៣០១. ១០៣

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០២៣*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

**យើង**

នស/រកត/០១២៣/ ៧០៤

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា )

**ត្រាស់បង្គាប់**

ផ្តល់គោរមងារ :

លោក **អ៊ាង គន្ធា**

ជា

**ឧកញ៉ា**

ចារល-ម៣០១.៧០៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/១០៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** បញ្ចូលក្របខ័ណ្ឌ និងផ្តល់ឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ដល់លោក **មាស ម៉ារិន** អត្តលេខ ០១១០៨៨ ។

**មាត្រា២ :** តែងតាំង និងផ្តល់ឋានៈ ដល់ ឯកឧត្តម ឧត្តមសេនីយ៍ត្រី **មាស ម៉ារិន** អត្តលេខ ០១១០៨៨ ជា ទីប្រឹក្សាក្រសួងការពារជាតិ មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានបង្គំគាល់ថ្វាយព្រះមហាក្សត្រ
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/ ១០៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** ៖ តែងតាំងមុខតំណែងឯកឧត្តម **នាង តារិទ្ធ** ជារដ្ឋលេខាធិការ នៃក្រសួងសុខាភិបាល។

**មាត្រា២** ៖ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុក អនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរស. ម៣០១. ១០៦

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែមករា ឆ្នាំ២០២៣*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រី ប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/ ១០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការនិងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំង និងផ្តល់ឋានៈឯកឧត្តម **តឹក ប៊ុនធឿន** ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បំណាច់មុខងារ។

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី

៣រាជ. ៤៣០១. ១០៧

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែមករា ឆ្នាំ២០២៣*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/ ៧០៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

## ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ដល់មន្ត្រីរាជការ និងសប្បុរសជន ៦៥រូបៈ

ក-**មេដាយជាតូបការ**

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១- | លោកជំទាវ | ឈួង | ចាលឹក | ៣- | ឯកឧត្តម | មីន | មករា |
| ២- | លោកជំទាវ | ហេង | ផាំង | ៤- | ឯកឧត្តម | ប៊ុន | វាសនា |

ខ-គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១- | លោកជំទាវ | ម៉ម | សម័យ | ១២- | លោកជំទាវ | សួស | បូណា |
| ២- | លោកជំទាវ | សម | ប្រាថ្នា | ១៣- | លោកជំទាវ | សោម | សោភា |
| ៣- | លោកជំទាវ | ប៉ាង | វាសនា | ១៤- | លោកស្រី | អ៊ុន | សុគន្ធីតា |
| ៤- | លោកជំទាវ | ណាន់ | ធិរ៉ា | ១៥- | លោកជំទាវ | មីន | សោភា |
| ៥- | វរសេនីយ៍ឯក | សេង | វង្ស | ១៦- | លោកជំទាវ | មួង | ទីកាវ៉ាត់ |
| ៦- | លោកជំទាវ | ហាយ | គន្ធា | ១៧- | លោកស្រី | វ៉ាន់ | សៃថៃ |
| ៧- | លោកជំទាវ | លី | គីមឡេង | ១៨- | លោកជំទាវ | ប៊ុន | ចន្ធូ |
| ៨- | លោកជំទាវ | គៀត | លីណា | ១៩- | លោកស្រី | ប៊ុន | លីហួរ |
| ៩- | លោកជំទាវ | ជូ | គីមស្រួយ | ២០- | លោក | អ៊ឹង | ចំរើន |
| ១០- | ឧកញ៉ា | មៀម | វណ្ណៈ | ២១- | លោកវេជ្ជបណ្ឌិត | ម៉ា | យុន |
| ១១- | លោក | អ៊ុក | សុភ័ក្រ្តា | | | | |

គ-គ្រឿងឥស្សរិយយស**មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១- | លោកជំទាវ | យុ | ភីន | ១១- | លោកជំទាវ | កាន់ | គីមយឿន |
| ២- | លោកជំទាវ | លឹម | សនទី | ១២- | លោកជំទាវ | អេត | ត្រីស្នា |
| ៣- | លោកជំទាវ | សាវ | សៃងច័ន្ទ | ១៣- | លោកស្រី | សៀង | គីមយ៉ាយ |
| ៤- | ឧត្តមសេនីយ៍ទោ | រ៉ូ | ពិសិដ្ឋ | ១៤- | លោកស្រី | គួ | ជីន |
| ៥- | ឧត្តមសេនីយ៍ទោ | មីន | រតនៈ | ១៥- | ឧកញ៉ា | មីន | កុម្ភៈ |
| ៦- | ឯកឧត្តម | រស់ | សារាំ | ១៦- | លោកស្រី | បូ | មុយស៊ីន |
| ៧- | ឧត្តមសេនីយ៍ត្រី | មីន | រស្មី | ១៧- | លោកស្រី | លី | ខេង |
| ៨- | លោក | តាំង | ហៀងឈុង | ១៨- | លោក | លៀម | ផេង |
| ៩- | លោក | សេង | វណ្ណដា | ១៩- | លោកជំទាវ | ម៉ែន | សោភ័ណ |
| ១០- | មហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ យន្ត ឈុនហួរ | | | | | | |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ឃ-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ **មហាសេនា**

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១- | លោកស្រី | មីន | ផុង | ១២- | លោក | ប្រសើរ | រ៉នី |
| ២- | លោក | ប៊ុន | គួង | ១៣- | លោក | កែវ | សុខា |
| ៣- | លោក | អេង | ឈុនឡាយ | ១៤- | លោក | ភាព | សុភា |
| ៤- | លោក | តាំង | ងួនហ៊ុយ | ១៥- | លោក | យី | សុខគង់ |
| ៥- | លោក | ជូ | គីមស្រ៊ុន | ១៦- | លោក | លីម | សោភណ្ឌ |
| ៦- | លោកស្រី | ណុប | ដាលីន | ១៧- | លោក | សេង | វៃ |
| ៧- | លោក | ឡេា | ក្រឹម | ១៨- | លោក | លីម | ខា |
| ៨- | លោក | ហុក | ច័ន្ទឆាយា | ១៩- | លោក | កង | សេត |
| ៩- | លោក | ងួន | ធីរៈ | ២០- | លោក | ងួន | ធឿន |
| ១០- | លោកស្រី | អ៊ីវ | កន្និកា | ២១- | លោក | ម៉ឹង | ចាន់ធឿន |
| ១១- | វរសេនីយ៍ឯក | ឃួន | ច័ន្ទមុន្នី | | | | |

នស.រកម.០១២៣.១០៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/ ១០៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **សៀង ស៊ុយ៉ុង** (XIANG. XUEYONG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៨៥ នៅខេត្ត Hubei សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **សៀង រ៉ូប៊ីន** (XIANG ROBIN)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ចាវលា-ម៣០១.១០៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/ ១១០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **វ៉ាង ជី** (WANG ZHI) ជនជាតិហ្គីណេ សញ្ជាតិហ្គីណេ កើតថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៨៧ នៅសាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរស. ២៣០១. ១១០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/ ៧១៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តាំងស៊ប់ ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងមុខងារសាធារណៈ ដល់មន្ត្រីរាជការ ០៩ រូប ចាប់ពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០២២៖

| | | | |
|---|---|---|---|
| ១-លោកស្រី | **ម៉ម ច័ន្ទម៉ារ៉ា** | អនុមន្ត្រី | ថ្នាក់លេខ ៤ |
| ២-លោក | **ពិត នៃណាយុទ្ធ** | អនុមន្ត្រី | ថ្នាក់លេខ ៤ |
| ៣-លោក | **សុខសម្បត្តិ សម្បូណ៍** | អនុមន្ត្រី | ថ្នាក់លេខ ៤ |
| ៤-លោកស្រី | **ឃី ស្រីរ័ត្ន** | អនុមន្ត្រី | ថ្នាក់លេខ ៤ |
| ៥-លោក | **មុំ ហុន** | អនុមន្ត្រី | ថ្នាក់លេខ ៤ |
| ៦-លោក | **និត ពិសិដ្ឋ** | អនុមន្ត្រី | ថ្នាក់លេខ ៤ |

៧-លោកស្រី **ស៊ី គីមលៀង** អនុមន្ត្រី ថ្នាក់លេខ ៤
៨-លោកស្រី **ឆាំ ឆារី** អនុមន្ត្រី ថ្នាក់លេខ ៤
៩-លោកស្រី **ពីខូ សុផាវក្សធេមី** អនុមន្ត្រី ថ្នាក់លេខ ៤

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

៣៩៧.២៣០១.១១១

នរោត្តមសីហមុនី

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០២៣*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/ ១៦៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ក្នុងឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម នៅក្រសួងអប់រំ យុវជន និងកីឡា តាមកម្រិតសញ្ញាបត្រ ដល់មន្ត្រីរាជការ ០៥ រូប៖

| | |
|---|---|
| ១-ឯកឧត្តម **ស៊ិន សេចហុក** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៥ មកជា ថ្នាក់លេខ ៤ |
| ២-លោក **សុខ ឬទ្ធី** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦ មកជា ថ្នាក់លេខ ៥ |
| ៣-លោក **ស៊ាន ម៉ុនសា** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦ មកជា ថ្នាក់លេខ ៥ |
| ៤-លោក **ហោច ផលរិត** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦ មកជា ថ្នាក់លេខ ៥ |
| ៥-លោក **ម៉ៅ ខយ** | ពីគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ មកជាគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស ថ្នាក់លេខ ៦ |

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៩៩. ៤៣០១.១៦៤

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ភិក្ខុនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/ ១១៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ក្នុងឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ និងក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងសុខាភិបាល តាមកម្រិតសញ្ញាបត្រ ដល់មន្ត្រីរាជការ **០៦ រូប ៖**

| | | |
|---|---|---|
| ១-លោក **ឌុក ឆមេឆ** | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ២-លោក **ស៊ឹម សុផៃ** | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៤ | មកជា ថ្នាក់លេខ ៣ |
| ៣-លោក **ហ៊ុយ វ៉េអុល** | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៥ | មកជា ថ្នាក់លេខ ៤ |
| ៤-លោក **សៀ ថុល** | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៥ | មកជា ថ្នាក់លេខ ៤ |

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

| | |
|---|---|
| ៥-លោក **ឈួយ គីមឆន** | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១<br>មកជាមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៦ |
| ៦-លោក **ស៊ី ទៀម** | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១<br>មកជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស ថ្នាក់លេខ ៦ |

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នស.រកត.០១២៣.១១៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី* ១៤ *ខែមករា ឆ្នាំ២០២៣*

សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/ ១១៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

## ត្រាស់បង្គាប់

**មាត្រា១:** ដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី តាមកម្រិតសញ្ញាបត្រ ដល់ឯកឧត្តម **សុខ សទ្ធារ** ពីឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ១ មកជាឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងទេសចរណ៍។

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានបម្លង់ត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសល្យបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/ ១១៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោធិ កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

## ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ដល់មន្ត្រីរាជការក្រសួងកិច្ចការនារី ៩រូបៈ

ក-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១- លោកជំទាវ ញាណ សុចិត្រា
២- លោកស្រី ជូ សុខជានី

ខ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

១- លោកស្រី សាវ គឹមសឿន
២- លោក ម៉ែន សម្បត្តិ
៣- លោកស្រី អ៊ុក ណានី
៤- លោកស្រី ភោគ សុភ័ក្រ
៥- លោកស្រី អ៊ាន ណារៀង
៦- លោកស្រី ថន គឹមស្រ៊ន់
៧- លោកស្រី ហែម ភូរី

៣៧៧.ចពា០១.១១៧

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

[Seal] [Signature]

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ព្រះរាជក្រឹត្យ

នស/រកត/០១២៣/ ១១៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ស៊ី ស៊ីង** (XU SHENG) ជនជាតិ ចិន សញ្ជាតិ ចិន កើតនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩២ នៅខេត្តហ៊ូប៉ី សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ហ៊ុន ស៊ីង** ( HUN SHENG )។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

៣៧៣.២៣០១.១១៩

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០២៣*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៨៤ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពី**
**គោលការណ៍ណែនាំសម្រាប់ការវិនិយោគមូលនិធិសន្តិសុខសង្គម**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៨៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
